**ជំពូកទី ៨**

# ពិការថ្លង់ និងការប្រាស្រ័យទាក់ទង (Deafness and Communication)

## កុមារម្នាក់ៗមានការបាត់បង់ផ្នែកសោតវិញ្ញាណខុសៗគ្នា

កុមារមួយចំនួន **ពិការថ្លង់ទាំងស្រុង** ពួកគេមិនអាចស្ដាប់ឮសំលេងអ្វីទាំងអស់។ ជាទូទៅឳពុកម្ដាយបានសំគាល់ថា កូនរបស់គាត់មិនអាចស្ដាប់ឮ ដោយសារគេមិនបានបែរក្បាលរបស់គេ ឬឆ្លើយតបមកវិញទេ ទោះជាសំលេងខ្លាំងជាងក៏ដោយ។



កុមារដែលថ្លង់ទាំងស្រុងមិនអាចឆ្លើយតបទេ ទោះជាសំលេងខ្លាំងយ៉ាងណាក៏ដោយ។ (ប៉ុន្តែវាអាចសំគាល់នូវចលនា ឬការញ័រដែលបណ្ដាលមកពីសំលេងខ្លាំងមួយភ្លែត)។ ឧទាហរណ៍ ទះដៃពីក្រោយក្បាលកុមារអាចធ្វើអោយខ្យល់ផាត់ប៉ះនឹងក ហើយធ្វើឱ្យគេងាក។

ជាទូទៅកុមារមាន**បញ្ហាត្រចៀក**ខ្លះៗ។ កុមារអាចបង្ហាញនូវភាពភ្ញាក់ផ្អើល និងបែរក្បាលរបស់គេនៅពេលឮសំលេងខ្លាំង ផ្ទុយទៅវិញគេមិនអាចឮនៅពេលប្រើសំលេងធម្មតានោះទេ។ គេអាចឆ្លើយតបទៅវិញនៅពេលឮសំលេងធ្ងន់ៗដូចជា រន្ទះបាញ់ ស្គរ ឬសំលេងគោស្រែក "ម៉ " ប៉ុន្តែគេស្ដាប់មិនឮចំពោះសំលេងស្រាលៗដូចជា ខ្សឹប ឬមាន់រងាវ។ ផ្ទុយទៅវិញ កុមារខ្លះៗ(មិនជាទូទៅ) អាចឆ្លើយតបទៅវិញ ចំពោះសំលេងស្ទូរស្រាលៗ ប៉ុន្តែស្ដាប់មិនឮចំពោះសំលេងធ្ងន់ៗទៅវិញ។



កុមារដែលស្ដាប់ឮខ្លះៗ អាចស្ដាប់ឮសំលេង ប៉ុន្តែគេមិនអាចស្ដាប់ឮច្បាស់គ្រប់គ្រាន់ ដើម្បីប្រាប់យើងអំពីភាពខុសគ្នានៃសំលេង និងពាក្យជាក់លាក់។ ជាទូទៅគ្រួសារ មានការយឺតយ៉ាវក្នុងការដឹងថា កូនរបស់គាត់មានបញ្ហាក្នុងការស្ដាប់។

កុមារខ្លះថ្លង់ ស្ដាប់ឮតិចៗ នៅពេលនិយាយទៅកាន់ពួកគេ។ ពួកគេអាចរៀនទទួលស្គាល់យឺតៗ និងឆ្លើយតបទៅនឹងពាក្យខ្លះ។ ប៉ុន្តែពាក្យជាច្រើន ពួកគេស្ដាប់មិនយល់ច្បាស់លាស់ទាំងអស់នោះទេ។ ជាធម្មតាពួកគេនិយាយមិនច្បាស់ គឺមានច្របូកច្របល់សូរសំលេង ឬហាក់បីដូចជានិយាយតាមច្រមុះ។ អកុសលជួនកាល ឳពុកម្ដាយកុមារផ្សេងទៀត លោកគ្រូ អ្នកគ្រូមិនបានចាប់អារម្មណ៍ថា កុមារមានបញ្ហាក្នុងការស្ដាប់ទៀតនោះ នោះពួកគាត់អាចគិតថា កុមារពិការមានបញ្ហាខួរក្បាល ឬថ្លង់។ នេះគឺជាការបង្កើននូវបញ្ហាដល់កុមារ។

**ការទំនាក់ទំនង** ជាវិធីដែលយើងយល់នូវអ្វី ដែលបាននិយាយ ដើម្បីប្រើប្រាស់ និងជាវិធីដែលយើងនិយាយ ឬ**សំដែងចេញ** ទៅអ្នកដទៃនូវការគិត តម្រូវការ និងអារម្មណ៍របស់យើង។ មនុស្សដែលអាចឮអំពីការទំនាក់ទំនង ខ្លាំងបំផុតតាមរយៈពាក្យសម្ដី។

### បញ្ហាអាចបណ្ដាលអោយ

ចំពោះកុមារវ័យជំទង់ ការស្ដាប់ និងពាក្យ គឺមានសារៈសំខាន់ណាស់ ដើម្បីស្វែងយល់និងយល់ដឹង ហើយទំនាក់ទំនងជាមួយមនុស្ស និងវត្ថុជុំវិញខ្លួនរបស់គេ។

ចំពោះកុមារដែលបាត់បង់ការស្ដាប់បញ្ហាដ៏ចំបង គឺការរៀនសំរាប់ធ្វើការប្រាស្រ័យទាក់ទងគ្នា ដោយសារគេមិនអាចស្ដាប់ឮពាក្យបានច្បាស់ ជាប្រការដ៏លំបាកសំរាប់គេក្នុងការរៀននិយាយ។ ហេតុដូច្នេះកុមារមានបញ្ហាទាំងការយល់នូវអ្វីដែលមនុស្សចង់បាន និងប្រាប់ត្រលប់មកវិញនូវអ្វីដែលកុមារចង់បានដែរ។ ប្រការនេះហើយដែលអាចនាំទៅរកការអស់សង្ឃឹម និងយល់ខុសពីគ្នាទៅវិញទៅមកសំរាប់ទាំងកុមារ និងមនុស្សទូទៅ។ វាមិនមែនជាការភ្ញាក់ផ្អើលនោះទេ ដែលកុមារមានបញ្ហាក្នុងការស្ដាប់ ជួនកាលពួកគេមានការយឺតយ៉ាវក្នុងការរៀនសូត្រ ដើម្បីទំនាក់ទំនងជាមួយមនុស្សដទៃ ហើយគេមានភាពឯកោ ឬចាញ់ប្រៀបគេ ឬឈានទៅរកបញ្ហាអាកប្បកិរិយាទៀតផង។

ការផ្លាស់ប្ដូរគំនិត និងពត៌មាន តាមរយៈការប្រាស្រ័យទាក់ទងមួយចំនួន ជាការសំខាន់មួយសំរាប់អភិវឌ្ឍចិត្តគំនិតរបស់កុមារ។ កុមារថ្លង់ភាគច្រើនមានប្រាជ្ញាឈ្លាសវៃ ដូចកុមារដទៃទៀតអញ្ចឹងដែរ។ ប៉ុន្តែដើម្បីឈានទៅដល់លទ្ធភាពផ្នែកខួរក្បាល ដ៏ពេញលេញ ពួកគេចាំបាច់ត្រូវចេះធ្វើការប្រាស្រ័យទាក់ទងអោយបានល្អ ចាប់ពីពេលដំបូង ឬកាលពីនៅតូចទៅ។

**តើភាពថ្លង់ ឬបាត់បង់ការស្តាប់ ឬប៉ះពាល់កុមារ** យោលទៅលើអ្វីខ្លះ:

១. **នៅពេលកុមារទៅជាថ្លង់:** ចំពោះកុមារថ្លង់ពីកំណើត ឬទៅជាថ្លង់មុនពេលគេចាប់ផ្តើមចេះនិយាយ ការរៀននិយាយ ឬអានបបូរមាត់នឹងមានការលំបាកច្រើនជាង កុមារដែលបាត់បង់នូវការស្តាប់ក្រោយពេលដែលគេរៀនចេះនិយាយ។

២. **តើកុមារនៅស្តាប់ឮប៉ុណ្ណា** -កុមារស្តាប់ឮបានល្អ សំលេងរៀននិយាយរបស់ពួកគេក៏កាន់តែល្អ យល់ដឹងពីការនិយាយស្តី និងរៀនមើលបបូរមាត់។

៣. **ពិការភាពដទៃទៀត:** កុមារមានផលវិបាកក្នុងការស្តាប់ខ្លះ មានបញ្ហាផ្សេងផងដែរ។ កុមារអាចមានការលូតលាស់ យឺតផ្នែកប្រាជ្ញា រួមជាមួយនឹងពិការភ្នែកទៀត នឹងមានការលំបាកក្នុងការរៀនសូត្រអោយចេះប្រាស្រ័យទាក់ទង ដែលលំបាកជាងកុមារដែលបញ្ហាក្នុងការស្តាប់តែមួយមុខ។ ⟶

៤. **តើត្រូវស្វែងរកបញ្ហាកុមារអោយបានឆាប់ឃើញយ៉ាងម៉េច។**

៥. **តើកុមារត្រូវបានទទួលយកយ៉ាងណា ហើយគេត្រូវបានជួយឆាប់យ៉ាងណាដើម្បីរៀននូវវិធីផ្សេងទៀតនៃការប្រាស្រ័យទាក់ទង។**

៦. **ប្រព័ន្ធ នៃការប្រាស្រ័យទាក់ទង** នឹងត្រូវបានបង្ហាត់បង្ហាញដល់កុមារ(និយាយផ្ទាល់ ឬនិយាយ និងស្តាប់ សូមមើលទំព័រ ៨៧)

**មូលហេតុដែលបណ្តាលទៅជាថ្លង់**

ការថ្លង់មិនបានបង្កឡើងដោយក្មេងធ្វើអ្វីខុសឆ្គង ឬមកអំពីអ្នកណាម្នាក់ បានធ្វើទោសឡើយ។

**ទាំងនេះជាមូលហេតុសាមញ្ញនៃផលវិបាកក្នុងការស្តាប់ :**

- **តពូជពង្ស:** (កើតឡើងចំពោះគ្រួសារខ្លះ ទោះបីឪពុកម្តាយរបស់គេមិនពិការថ្លង់ក៏ដោយ)។ ជាទូទៅកុមារមិនមានពិការភាពផ្សេងទៀត ហើយគេរៀនចេះឆាប់រហ័ស។
- **ជំងឺកញ្ជ្រឹល:** អំឡុងពេលមានគភ៌។ ជាទូទៅ កុមារមានការខូចផ្នែក ខួរក្បាល និងមានបញ្ហារៀនសូត្រ។
- **កត្តា Rh** (សូមមើលទំព័រ ២៣) ជាទូទៅ កុមារមានពិការភាពផ្សេង ទៀតដែរ។
- **ទារកកើតមុនខែ:**(ទារកកើតមិនគ្រប់ខែ)ក្នុងចំណោម៣មាន ២នាក់ មានពិការភាពផ្សេងទៀតដែរ
- **កង្វះជាតិអ៊ីយ៉ូត** ការតមរបស់ម្តាយ (ជាធម្មតា មនុស្សជាច្រើនមានជំងឺពកក)។ មនុស្សជាច្រើន បានបង្ហាញនូវ សញ្ញាណជំងឺលូតលាស់យឺតនៃខួរក្បាល និងបញ្ហាសរសៃប្រសាទ (សូមមើលទំព័រ ១០៦)
- **ការប្រើប្រាស់ថ្នាំ** នៅពេលម្តាយមានគតិដូចជា corticosteroids and phenytoin
- ពិបាកក្នុងការប្រសូត្រ កុមារមានការយឺតយ៉ាងក្នុងការដកដង្ហើម
- ជំងឺគ្រុន និងជំងឺឆ្អឹងស្រួយ




**មូលហេតុសាមញ្ញៗ ក្រោយពេលកើត**

- **ជំងឺត្រចៀក** -ជាពិសេស ការឆ្លងជំងឺយ៉ាងយូរ និងមានខ្ទុះ
- **ជំងឺរលាកស្រោមខួរ:** កើតឡើងចំពោះកុមារមានពិការ-ភាពផ្សេងទៀត និងបញ្ហា អាកប្បកិរិយា
- **ការប្រើប្រាស់ថ្នាំគ្មានសុវត្ថិភាព** (Streptomycin and related antibiotics)
- **ការស្តាប់សំលេងឮលាន់ខ្លាំង**

**មូលហេតុផ្សេងទៀត** មានមូលហេតុផ្សេងទៀតជាច្រើន ដែលបណ្តាល ទៅជាពិការថ្លង់។ កុមារម្នាក់ក្នុងចំណោមកុមារ៣នាក់បង្ហាញពីមូលហេតុ មិនជាក់លាក់។

## សារៈសំខាន់ នៃការសំគាល់ពិការថ្លង់អោយទាន់ពេលវេលា

ក្នុងកំឡុងពេលឆ្នាំទីមួយនៃជីវិតរស់នៅ ចិត្តគំនិតរបស់កុមារនៅស្អាតល្អ គេរៀនភាសាចេះយ៉ាងឆាប់រហ័ស។ ប្រសិនបើបញ្ហាស្តាប់របស់កុមារមិនបានសំគាល់អោយទាន់ពេលវេលា និងមិនបានជួយប្រកបដោយប្រសិទ្ធភាព។ ឆ្នាំដ៏ប្រសើរនៃការរៀនជំនាញប្រាស្រ័យទាក់ទងអាចត្រូវបានបាត់បង់(អាយុ0 ដល់ ៧ឆ្នាំ)។ **ការចាប់ផ្តើមបណ្តុះបណ្តាលពិសេសកាន់តែឆាប់ ពេលណាកុមារអាចរៀនប្រាស្រ័យទាក់ទងបានច្រើនពេលនោះដែរ**។

ឪពុកម្តាយគួរមើលយ៉ាងយកចិត្តទុកដាក់ទៅលើ **សញ្ញាណដែលបង្ហាញថាកុមារអាចស្តាប់ឮ និងមិនស្តាប់ឮ**។ តើទារកបង្ហាញនូវការភ្ញាក់ផ្អើល ឬព្រិចភ្នែក នៅពេលដែលអ្នកធ្វើអោយមានសំលេងឮខ្លាំងដែរឬទេ? នៅពេលទារកលូតលាស់បន្តិចម្តងៗ តើគេងាកក្បាល ឬសើច នៅពេលគេឮសំលេងដែរឬទេ? តើកុមារចាប់ផ្តើមនិយាយពាក្យពីរបីម៉ាត់ នៅពេលកុមារអាយុ១៨ ខែ ដែរឬទេ? តើកុមារនិយាយច្រើនពាក្យច្បាស់ៗ នៅពេលអាយុ ៣ ដល់ ៤ ឆ្នាំ ដែរឬទេ? ប្រសិនបើនិយាយមិនបាននោះទេ គេអាចបញ្ហាក្នុងការស្តាប់។ នៅពេលដែលអ្នកសង្ស័យថាកុមារមានបញ្ហា ត្រូវធ្វើតេស្តការស្តាប់របស់កុមារភ្លាម។

**ការធ្វើតេស្តការស្តាប់ដ៏សាមញ្ញ**។ ប្រសិនបើគិតថា កុមារស្តាប់បានសំលេងឮខ្លះៗ នៅពេលសមស្រប ត្រូវយកកុមារទៅជួបអ្នកជំនាញដើម្បីធ្វើតេស្ត។

ប្រសិនបើកុមារ មិនបានយល់ដឹងច្រើន និងមិនបានទទួលឱកាសក្នុងការរៀនប្រាស្រ័យទាក់ទងនៅពេលអាយុតិចទេ **ពិការថ្លង់អាចក្លាយជាពិការភាពដ៏លំបាកធ្ងន់ធ្ងរ មានភាពឯកោ និងគួរអោយច្រលំក្នុងការសំគាល់បញ្ហានោះ**។ ករណីរឿងពីរខាងក្រោមនេះនឹង ជួយបង្ហាញនូវភាពខុសគ្នាថា ដែលថាអាចសំគាល់បញ្ហាក្នុងការស្តាប់បានឆាប់ ហើយផ្តល់ជំនួយបន្ថែមដែលកុមារត្រូវការ។

## តូនីអូ

ថ្វីបើ តូនីអូ កើតមកមានបញ្ហាក្នុងការស្តាប់ក៏ពិតមែន ប៉ុន្តែឪពុកម្តាយ មិនបានសំគាល់ឃើញបញ្ហានេះ រហូតដល់គេអាយុ ៤ ឆ្នាំ។ ពេលកន្លងផុតទៅយ៉ាងយូរពួកគេគិតថា តូនីអូ ជាកុមារយ៉ាប់ ឬរឹងរូស។

រហូតមកដល់ តូនីអូ អាយុបាន ១ឆ្នាំ។ តូនីអូ ហាក់បីដូចជាបានធ្វើការងារយ៉ាងល្អ។ គេបានចាប់ផ្តើមដើរនិងលេងជាមួយវត្ថុអ្វីៗ។ បន្ទាប់មកប្អូនស្រីរបស់គេឈ្មោះ ឡូតា បានកើតមក។ ឡូតា ញញឹម និងសើចច្រើនជាង តូនីអូ នៅពេលដែលម្តាយរបស់គេបាននិយាយទៅកាន់ ឬច្រៀងទៅកាន់នាង។ ដូច្នេះម្តាយរបស់គេបាននិយាយ និងច្រៀងអោយ ឡូតា ស្តាប់ជាបន្តទៀត។

កាលនោះ ឡូតា អាយុបាន១ឆ្នាំ។ នាងតែងតែចាបផ្តើមនិយាយពីរបីម៉ាត់។ តូនីអូ មិនទាន់បានចាប់ផ្តើមនិយាយស្តីអ្វីឡើយ។ មានថ្ងៃមួយអ្នកជិតខាងបានសួរថា " តើអ្នកប្រាកដថាគេអាចស្តាប់ឮទេ? "។ ហើយម្តាយគេបានឆ្លើយថា"ចាំសស្តាប់បាន "។ គាត់បានហៅឈ្មោះ គេឮខ្លាំងៗ ហើយ តូនីអូ បានងាកក្បាលមកកាន់សំលេងនោះ។

នៅពេលដែល តូនីអូអាយុបាន៣ ឆ្នាំ គេអាចនិយាយតែពីរបី ម៉ាត់តែប៉ុណ្ណោះ ហើយចំពោះឡូតា នៅពេលអាយុបាន២ឆ្នាំ និយាយបានច្រើនរហូតដល់ ២០០ ពាក្យ។ នាងបានសួររកវត្ថុផ្សេងៗ ច្រៀងចំរៀង សា-មញ្ញៗ និងលេងជាមួយកុមារដទៃយ៉ាងសប្បាយរីករាយទៀតផង។ តូនីអូមានការខឹងសម្បាយ៉ាងខ្លាំង ព្រោះភាគច្រើនគេលេងតែម្នាក់ឯង។ នៅពេលគេលេងជាមួយកុមារដទៃទៀត មានតែការវាយតប់ ឬយំស្រែកតែប៉ុណ្ណោះ។

ឡូតា បានប្រព្រឹត្តិនូវអាកប្បកិរិយាល្អជាងតូនីអូ។ ជាធម្មតានៅពេលម្តាយរបស់គេបានប្រាប់គេកុំអោយធ្វើអ្វីមួយ និងមូលហេតុទាំងឡាយនោះ។ នាងតែងតែយល់ និងធ្វើតាមការណែនាំទាំងនោះ។ ជារឿយៗដើម្បីអោយតូនីអូ ធ្វើតាមការណែនាំនោះ ម្តាយរបស់គេតែងតែវាយគេ។

នៅថ្ងៃមួយនៅក្នុងផ្សារតាមភូមិ ឡូតា បានសួររកទិញផ្លែចេក ហើយម្តាយរបស់គេបានទិញមួយអោយនាង។ មួយស្របក់ក្រោយមក តូនីអូ បានលូកយកផ្លែស្វាយមកញ៉ាំ។ នៅពេលនោះម្តាយរបស់គេបានវាយគេ។ ភ្លាមនោះតូនីអូបានគ្រវាញចោលទៅដី និងទាត់ចោលហើយស្រែកយំតែម្តង។

នៅពេលឪពុករបស់តូនីអូ បានឮសំលេងស្រែកនៅក្នុងផ្សារគាត់មានការខឹងសម្បាយ៉ាងខ្លាំង ហើយបាននិយាយថា"តើនៅពេលណា ដែលឯងចេះសួររករបស់អ្វីផ្សេងៗ?"ឥឡូវឯងអាយុ៤ឆ្នាំ ហើយនៅតែមិនព្យាយាមនិយាយអ្វីបន្តិចសោះ តើឯងឆ្កួតឬក៏ឡប់?



តូនីអូ គ្រាន់តែសំលឹងមើលមុខឪពុកបន្តិច។ ពេលនោះ ទឹកភ្នែកបានហូរមកលើថ្ពាល់របស់គេ។ គេមិនអាចយល់នូវអ្វីដែលឪពុករបស់គេបាននិយាយទៅកាន់គេទេ។ ប៉ុន្តែគេបានយល់ថា ឪពុករបស់គេខឹងនឹងគេ។ ឪពុករបស់គេក៏គៀកដៃគេ ហើយនាំមកផ្ទះវិញ។

អាកប្បកិរិយារបស់តូនីអូទៅឈានទៅរកស្ថានភាពយ៉ាប់ទៅៗ។ នៅពេលអាយុ ៤ឆ្នាំ ម្តាយរបស់គេបានយកទៅជួបនឹងបុគ្គលិក សុខភាពដែលបានធ្វើតេស្ត ហើយរកឃើញថា តូនីអូ ប្រាកដជាថ្លង់ មែន។

បច្ចុប្បន្ន ឪពុកម្តាយរបស់តូនីអូ បានព្យាយាមបំពេញនូវពេលវេលាដែលបាត់បង់កន្លងមក ហើយពួកគេព្យាយាមនិយាយទៅកាន់គេ យ៉ាងច្បាស់ និងយឺតៗ។ នៅពេលមានពន្លឺគ្រប់គ្រាន់ល្អ ពួកគេបានប្រើភាសាសញ្ញា និងកាយវិការ ជាមួយនឹងដៃរបស់គេ ដើម្បីជួយធ្វើយ៉ាងណា អោយគេបានយល់។ តូនីអូ ហាក់ដូចជាមានអារម្មណ៍សប្បាយរីករាយ មួយក៏រិតហើយចេះនិយាយពីរបីពាក្យ។ ប៉ុន្តែគេនៅមានបញ្ហាច្រើនទៅលើការនិយាយនូវអ្វីដែលគេចង់និយាយ។

## សាន់ជ្រា

នៅពេលដែលនាងមានអាយុ ១០ខែ។ បងប្រុសរបស់នាងមានឈ្មោះ **លីណូ** ដែលមានអាយុ៧ឆ្នាំបាន រៀនអំពីការធ្វើតេស្តពិការថ្លង់ដែលជាផ្នែកមួយនៃកម្មវិធីសកម្មភាពកុមារដើម្បីកុមារនៅសាលារៀន។ ដូច្នេះគេបានធ្វើតេស្តប្អូនស្រីដ៏តូចរបស់គេ។ នៅពេលគេឈរក្រោយនាងហើយហៅឈ្មោះនាង ឬគោះកណ្តឹង នាងមិនបានងាកឬធ្វើភ្នែកព្រិចនោះទេ។ ប៉ុន្តែនាងបានភ្ញាក់ព្រើតនៅពេលដែលគោះខ្ទះខ្លាំង។ គេបានប្រាប់ឪពុកម្តាយរបស់គេ ដោយគិតថានាង **សាន់ជ្រា** ស្តាប់មិនឮល្អទេ។ ពួកគេបាននាំ **សាន់ជ្រា** ទៅមណ្ឌលស្តារក្នុងភូមិ។ បុគ្គលិកបានធ្វើតេស្ត **សាន់ជ្រា** ហើយបានបញ្ជាក់ថានាងមានបញ្ហាក្នុងការស្តាប់យ៉ាងធ្ងន់ធ្ងរពិតប្រាកដមែន។

បុគ្គលិកភូមិបានពន្យល់នូវ អ្វីដែលក្រុមគ្រួសារអាចធ្វើបានដើម្បីជួយដល់ **សាន់ជ្រា** មានឱកាសអភិវឌ្ឍន៍ និងរៀនធ្វើការប្រាស្រ័យទាក់ទង។ បុគ្គលិកភូមិនោះបានអោយ រូបគំនូរនៃការប្រើប្រាស់ដៃ ធ្វើជាសញ្ញាសំរាប់ការប្រើពាក្យ ក្នុងការប្រាស្រ័យទាក់ទងគ្នា។

គ្រប់ពេលដែល អ្នកនិយាយ អ្នកធ្វើសញ្ញាដោយប្រើដៃដើម្បីបង្ហាញអំពីអត្ថន័យ។ ការប្រាស្រ័យទាក់ទងបែបនេះត្រូវប្រើទាំងសញ្ញា និងកាយវិការ ដែលអ្នករាល់គ្នាធ្លាប់ប្រើក្នុងភូមិ។ បង្រៀនកុមារផ្សេងទៀតអោយប្រើសញ្ញានេះផងដែរ។ លើសពីនេះទៅទៀតត្រូវធ្វើជាល្បែងដែលចេញពីសញ្ញាទាំងនេះ។ ដំបូង **សាន់ជ្រា** មិនយល់ទេ ប៉ុន្តែក្រោយមកនាងមើល និងរៀនកាត់យល់។ ពេលនោះហើយដែលនាងបានចាប់ផ្តើម ប្រើសញ្ញាដោយខ្លួននាង ផងដែរ។

ពួកគេបានសួរថា: "ប្រសិនបើនាងទំលាប់ប្រើសញ្ញា តើយើងមិនចាំបាច់បង្រៀននាងអោយនិយាយចេញទេឬ"?

បុគ្គលិកបានឆ្លើយថា:"មិនមែនអញ្ចឹងទេ បើមិនដូច្នោះទេ អ្នកគប្បីនិយាយចេញជាពាក្យនៅពេលនោះ ដូចគ្នាតែម្តង "។ សញ្ញានឹង ជួយនាងអោយយល់ពីពាក្យហើយនាងអាចនិយាយបានឆាប់ ប៉ុន្តែចំណាយពេលវេលាច្រើនដើម្បីរៀននិយាយជាមួយ"ការអានបបូរមាត់ " ដំបូងនាងចាំបាច់ត្រូវរៀនប្រើសញ្ញា ដើម្បីនិយាយនូវអ្វីដែលនាងចង់និយាយ ហើយវាអាចអភិវឌ្ឍន៍ចិត្ត គំនិតរបស់នាងទៀតផង។

គ្រួសាររបស់ **សាន់ជ្រា** បានចាប់ផ្តើមប្រើសញ្ញា នៅពេលដែលពួកគេនិយាយគ្នាទៅវិញទៅមក។ ជាច្រើនខែកន្លងផុតទៅ **សាន់ជ្រា** នៅតែមិនអាចនិយាយស្តីចេញ ឬធ្វើសញ្ញាចេញទេ ប៉ុន្តែឥឡូវនាងបានខំមើលអោយកាន់តែជិត។

អាយុ៣ឆ្នាំ **សាន់ជ្រា**បានចាប់ផ្តើមធ្វើសញ្ញា នៅពេលអាយុបាន ៤ ឆ្នាំ នាងអាចនិយាយបាន ហើយយល់បានយ៉ាងច្រើន អំពីការប្រើសញ្ញារួមជាមួយនោះ។ ទោះបីបើការអានបបូរមាត់មានតែពាក្យពីរ បី ម៉ាត់ក៏ពិតមែនដូចជាពាក្យ "បាទ ,ចាំស,ទេ " និង " **លីណូ** "។ នៅពេលអាយុបាន៥ឆ្នាំនាងបានប្រើការអានបបូរមាត់បានពាក្យពីរបីម៉ាត់។ ប៉ុន្តែជាមួយនឹងការប្រើសញ្ញា នាងអាចនិយាយបានលើសពី១០០ពាក្យ ហើយកាត់យល់ប្រយោគជាសាមញ្ញៗ ជាច្រើនទៀតផង។



**សាន់ជ្រា** មានការរីករាយណាស់ និងឧស្សាហ៏ព្យាយាមទៀតផង ។នាងចូលចិត្តរូបភាពដែលមានពណ៌ និងលេងទាយល្បែងផ្សេងៗ។ **លីណូ**បានចាប់ផ្តើមង្រៀននាងពីរបៀបគូរជារាងអក្សរ ។មានថ្ងៃមួយនាងបានសួរទៅកាន់**លីណូ**ថា "តើនៅពេលណាដែលនាងអាចទៅរៀនបាន "?

## កន្លែងណាដែលអ្នកអាចជួយបាន ?

កុមារដែលស្តាប់មិនសូវឮច្បាស់នឹងត្រូវបានជំនួយបន្ថែម ។ នៅកន្លែងណាដែលអ្នកអាចស្វែងរកជំនួយនេះ គឺអាស្រ័យនៅលើកន្លែងដែលអ្នកកំពុងរស់នៅ និងធនធានអ្វីដែលមាននៅក្នុងភូមិសហគមន៍ និងប្រទេសរបស់អ្នក ។ ខាងក្រោមនេះជាលទ្ធភាពមួយចំនួនដើម្បីជួយ:

- **មនុស្សថ្លង់នៅក្នុងស្រុកភូមិជាគ្រូបង្ហាត់:** ទោះបីជាភូមិតូចពិតមែន ប៉ុន្តែវាតែងតែមានមនុស្សខ្លះថ្លង់យូរមកហើយ ។ ប្រហែលជា ពួកគេបាន នឹងកំពុងរៀនប្រាស្រ័យទាក់ទងគ្នាតាមរយៈសញ្ញានិងកាយវិការ ។ ប្រសិនបើអ្នកអាចស្នើរសុំគេអោយជួយធ្វើជាមិត្តភ័ក្តិ និងជាគ្រូ កូនដែលគថ្លង របស់អ្នកនឹងអាចជាអ្នកពិគ្រោះយោបល់ដល់គ្រួសារ ជាការពិតគឺពួកគេសប្បាយនឹងធ្វើការងារនេះ ។ ពួកគេអាចចងចាំនូវការលំបាក និងភាពឯកោនៅពេលដែលគេនៅតូច ហើយនេះអាចធ្វើអោយគេមានចិត្តចង់ជួយធ្វើយ៉ាងណា អោយកុមារថ្លង់ជំនាន់ក្រោយបានយល់ និងទទួលបាននូវឱកាសដែលកុមារថ្លង់ចង់បាន ។



មនុស្សថ្លង់ដែលរៀនប្រាស្រ័យទាក់ទងបានល្អ ដូចនេះគេជាគ្រូដ៏សំខាន់បំផុតរបស់អ្នក គថ្លង់ និងគ្រួសាររបស់អ្នក ។

ពិសេសខ្លាំងណាស់ចំពោះមនុស្សថ្លង់ដែលអាចជាប្រយោជន៏ប្រសិនបើពួកគេបានរៀនពី "ភាសាសញ្ញាជាតិ" ។ និងអាចប្រាស្រ័យទាក់ទងបានពេញលេញជាមួយអ្នកគថ្លង់ដទៃទៀត ។ ប្រសិនបើគ្មានអ្នកគថ្លង់ ក្នុងភូមិអ្នកទេនោះអាចមាននៅភូមិជិតៗនោះ ប្រហែលជាកុមារអាចទៅលេងជាមួយអ្នកគ ថ្លង់នោះ ឬបង្កើតជាក្រុមមនុស្សថ្លង់ ។

- **គ្រួសារដទៃដែលមានកូនថ្លង់:** " ប្រសិនបើគ្រួសារមួយចំនួនដែលមានកូនថ្លង់អាចមករួមគ្នា ផ្លាស់ប្តូរបទពិសោធន៏ និងរៀនជាក្រុមនេះគឺជាជំនួយដ៏ល្អបំផុត ។ កុមារថ្លង់ដែលតូចជាងគេអាចរៀនពីមនុស្សថ្លង់ចាស់ៗ ឬក្មេងជំទង់ដែលថ្លង់ដូចគ្នា ។ ការសាមគ្គីគ្នានេះពួកគេអាចបង្កើតបាននូវទំរង់នៃការប្រាស្រ័យទាក់ទងគ្នា ។ ដូចនេះកុមារទាំងអស់ និង គ្រួសាររបស់គេអាចយល់គ្នា ទៅវិញទៅមកបាន ។
- **សមាគមន៏មនុស្សថ្លង់ថ្នាក់ជាតិ:** ឬក្រុមផ្សេងទៀតដែលដឹកនាំមនុស្សថ្លង់មួយក្រុម ។ នៅបណ្តាប្រទេសជាច្រើនមានសមាគមន៏ មនុស្សថ្លង់ ។ ទាំងនេះអាចផ្តល់ពតិមានដល់អ្នក អំពីភាសាសញ្ញាថ្នាក់ជាតិនៅក្នុងប្រទេសរបស់អ្នក និងអាចផ្ញើសៀវភៅសំរាប់យកទៅរៀនបន្ត ។ ពួកគេអាចប្រាប់អ្នកអំពីកម្មវិធីបណ្តុះបណ្តាលសំរាប់មនុស្សថ្លង់ ។ (រដ្ឋាភិបាលឯកជន និងសាសនា) ហើយអាចផ្តល់យោបល់ថា មួយណាល្អជាងគេ ។ ពួកគេអាចផ្តល់វគ្គបណ្តុះបណ្តាលខ្លីៗជាជំនាញប្រាស្រ័យទាក់ទង ជាមូលដ្ឋានទៅអោយបុគ្គលិកសុខភាពតាមភូមិ គ្រូបង្រៀនសមាជិកគ្រួសារ ឬកុមារពិការដែលគិតថាគាត់ អាចទៅបង្រៀនអ្នកផ្សេងទៀតបាន ។
- **កម្មវិធីអប់រំពិសេសឬសាលាកុមារគថ្លង់:** ប្រទេសជាច្រើនមានសាលាសំរាប់កុមារគថ្លង់ ដែលអាចរស់នៅដើម្បីទទួលការបណ្តុះបណ្តាលពិសេស ។ សាលាទាំងនេះមួយចំនួនល្អមែនប៉ុន្តែខ្លះមិនល្អទេ ។ កម្មវិធីល្អនឹងប្រើគ្រប់វិធីសាស្ត្រ ដើម្បីប្រាស្រ័យទាក់ទងទាំងអស់ ជាមួយកុមារម្នាក់ៗ ហើយត្រូវផ្តោតទៅលើអ្វីដែលអាចធ្វើទៅបានប្រសើរ សំរាប់កុមារក្នុងសហគមន៏ ។ កម្មវិធីមិនសមស្រប និងធ្វើយ៉ាងណាអោយកុមារថ្លង់ ចេះប្រាស្រ័យទាក់ទងដោយប្រើការអាន បបូរមាត់ ឬនិយាយស្តី ។ ចំពោះកុមារភាគច្រើនធ្វើ បែបនេះអាចទទួលបរាជ័យខឹងសម្បា និងមានអារម្មណ៏ហួរហួង (សូមមើលទំព័រ ៨៩) ។ ព្យាយាមរៀនសូត្រ និងទទួលយោបល់ពីអ្នក គថ្លង់ដែលមានការអប់រំល្អ ។

ដំបូងវាអាចពិបាកដល់ឪពុកម្តាយដែលអោយកូនចេញឆ្ងាយពីផ្ទះទៅសាលារៀន "ប៉ុន្តែការរៀនប្រាស្រ័យទាក់ទងដ៏ល្អ ជាបច្ច័យសំរាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់កុមារថ្លង់" ។ ធានានូវការពិនិត្យលើតំលៃ និងធ្វើផែនការទៅមុខ ។ សាលារៀនខ្លះអាចឥតបង់ថ្លៃ ឬបង់ថ្លៃឈ្នួលតិចតួច ។

## សំរេចនូវអ្វីដែលធ្វើសំរាប់កុមារថ្លង់

មិនមែនកុមារដែលមានបញ្ហាក្នុងការស្តាប់ទាំងអស់ដូចៗគ្នានោះទេ។ កុមារទាំងអស់ត្រូវការសេចក្តីស្រឡាញ់យល់ និងជួយក្នុងការរៀនប្រាស្រ័យទាក់ទង។ **ប៉ុន្តែកុមារម្នាក់ៗត្រូវការជំនួយខុសៗគ្នា ដើម្បីធ្វើការប្រាស្រ័យទាក់ទងតាមវិធីផ្សេងៗដែលជាមធ្យោបាយដ៏ល្អសំរាប់ពួកគេ។ យើងត្រូវសំរួលនូវវិធីរបស់យើងទៅតាមតំរូវការរបស់កុមារម្នាក់ៗ និងស្ថានភាពជាក់ស្តែងនៅក្នុងសហគមន៍ដែលពួកគេកំពុងរស់នៅ**។

- ប្រសិនបើកុមារគ្រាន់**តែថ្លង់បន្តិចបន្តួច** ជួនកាលយើងអាចជួយគេអោយស្តាប់ឮបានច្បាស់លាស់ (សូមមើលទំព័រ ៨៦) ដើម្បីយល់ដឹងអំពីការនិយាយបានច្រើន ហើយប្រហែលរៀននិយាយ។

- កុមារដែល**ថ្លង់ទាំងស្រុង**គេពុំអាចទទួលការជួយដើម្បីស្តាប់ឮបានទេ ប៉ុន្តែបើគេ**ថ្លង់ក្រោយចាប់ផ្តើមចេះនិយាយ**ប្រហែលគេអាចទទួលការជួយអោយអានបបូរមាត់អ្នកនិយាយដើម្បីពង្រឹងការនិយាយរបស់គេ។

- ប្រសិនបើកុមារ**កើតមានការថ្លង់ពីកំណើត និងនិយាយមិនចេញ** ការរៀនអានបបូរមាត់ និងនិយាយស្តី គឺតែងតែជួបការលំបាក និងយឺតយ៉ាវបំផុត ហើយជារឿយៗមិនសូវទទួលបានជោគជ័យទេ។ សំខាន់នោះត្រូវជួយកុមារអោយរៀន ប្រាស្រ័យទាក់ទងតាមវិធីណាដែលល្អចំពោះគេដូចជាដំបូង ជាមួយទឹកមុខរបស់គេ កាយវិការដៃ និងប្រអប់ដៃ ហើយបន្ទាប់មកបន្ថែមរូបភាព ការអាន ការសរសេរ ការប្រកបអក្សរតាមម្រាមដៃ និងការប្រើការអានបបូរមាត់ និងនិយាយច្រើនវាអាចជួយនាងអោយរៀនអក្សរបាន។

- ប្រសិនបើកុមារ មកពី**តំបន់ដែលមានមនុស្សថ្លង់** ដែលធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ដោយការប្រើភាសាសញ្ញាជាតិ វាជាមធ្យោបាយមួយដ៏ល្អ ដើម្បីអោយមនុស្សជួយមនុស្សថ្លង់ក្នុងសហគមន៍ ជួយបង្រៀនកុមារនិងគ្រួសាររបស់គេនូវភាសានោះ។ វិធីនេះនាងអាចរៀនប្រាស្រ័យទាក់ទងជាមួយមនុស្ស ថ្លង់អោយពេញលេញ និងយ៉ាងល្អ ដូចមនុស្សស្តាប់ឮដែលប្រាស្រ័យទាក់ទងជាមួយដូច្នេះដែរ។

- ប៉ុន្តែប្រសិនបើកុមាររស់នៅក្នុងភូមិតូចមួយដែលមានមនុស្សថ្លង់ពីរ បីនាក់ ហើយអ្នកទាំងនោះមិនចេះភាសាសញ្ញាជាតិ ដូច្នេះការរៀនភាសានោះមិនអាចជួយអោយកុមារបានច្រើនទេ។ ប្រហែលជាវិធីដ៏ល្អ ទៅអោយកុមាររៀននូវវិធីផ្សេងៗដើម្បីប្រាស្រ័យទាក់ទង ជាមួយមនុស្សធម្មតាដែលអាចស្តាប់ឮបាន។ ម្តងទៀតនេះប្រហែលមានន័យថាការបញ្ចូលគ្នានូវវិធីសាស្ត្រផ្សេងដោយផ្អែកទៅលើសញ្ញា និងកាយវិការដែលមនុស្សធ្លាប់ប្រើក្នុងភូមិនោះ។ ជាមួយគ្នានេះដែរ កុមារអាចប្រើនូវរូបភាពផងដែរ ហើយបន្ទាប់មកប្រហែលជា ការអាន និងការសរសេរ។

- ចងចាំថាកុមារភាគច្រើន ដែលមានបញ្ហាក្នុងការស្តាប់ អាចរៀនសូត្របានលឿន។ ប៉ុន្តែកុមារខ្លះអាចមានបញ្ហាខូចខួរក្បាល ឬពិការភាពផ្សេងៗ ដែលប៉ះពាល់ដល់ការរៀន ឬគ្រប់គ្រងដៃ បបូរមាត់ ឬសំលេងរបស់គេ។ អ្នកនឹងចេះរកវិធីផ្សេងៗ ដើម្បីជួយដល់កុមារទាំងនេះ ធ្វើការប្រាស្រ័យទាក់ទងតាមវិធីផ្សេងៗដែលគេអាចធ្វើបានដូចជា ជាមួយរូបភាពចលនាចល័ត នៃក្បាល ឬភ្នែក។

***ចំណាំ*** : កុមារខ្លះដែលមានសោតវិញ្ញាណល្អ មិនមានការរីកចំរើនខ្លាំងទៅលើលទ្ធភាពក្នុងការនិយាយ។ កុមារខ្លះដែលមានជំងឺខូចខួរក្បាលបញ្ហាចលនា មិនអាចគ្រប់គ្រងមាត់ និងអណ្តាតបានល្អក្នុងការនិយាយ។ កុមារដទៃទៀតដែលមានបញ្ហាខួរក្បាល ហើយអាចមានការយឺតយ៉ាវក្នុងការរៀននិយាយ ឬមិនដែលធ្លាប់រៀន "កុមារដទៃទៀតមានការឆ្លាតវៃតាមវិធីជាច្រើន ប៉ុន្តែមូលហេតុខ្លះគេមិនអាចនិយាយបាន។ ចំពោះកុមារទាំងនេះ យើងត្រូវរិះរកវិធីផ្សេងៗ ដើម្បីជួយពួកគេ អោយអាចប្រាស្រ័យទាក់ទងគ្នាបានល្អ ដែលឯងអាចធ្វើទៅបាន។

## វិធីជួយកុមារអោយស្តាប់ឮបានល្អ

កុមារដែលស្តាប់ឮបានខ្លះៗ ជួនកាលអាចត្រូវបានគេជួយស្តាប់បានល្អវិញៈ

- នៅពេលណាសមស្រប ចូរធ្វើតេស្តនូវការស្តាប់នឹងត្រចៀករបស់គេដោយអ្នកជំនាញ។ កុមារខ្លះកើតមកមានត្រចៀកបិទជិត ឬបញ្ហាផ្សេងៗក្នុងប្រព័ន្ធត្រចៀក។ បញ្ហាវាកំរនឹងត្រូវបានកែលំអដោយការវះកាត់ណាស់ ហើយកុមារអាចស្តាប់ឮបានល្អ(ចំណាំ : ចំពោះកុមារដែលមានបញ្ហាក្នុងការស្តាប់ អាចមកពីបញ្ហាខួរក្បាល ការវះកាត់មិនអាចជួយបានទេ)។
- កុមារដែលមានបញ្ហាក្នុងការស្តាប់ដោយសារ ជំងឺឆ្លងក្នុងត្រចៀក ដែលចាប់ផ្តើមស្តាប់ ឮច្បាស់វិញប្រសិនបើការឆ្លងក្នុងត្រចៀកត្រូវបានព្យាបាលទាន់ពេលវេលា ហើយមានជំហានដើម្បីបង្ការនូវជំងឺឆ្លងទាំងនោះ(សូមមើលទំព័រ ១០០)។
- កុមារខ្លះអាចស្តាប់ឮបានល្អ ដោយសារមានឧបករណ៍ដែលមានបន្លឺសំលេងខ្លាំង។ "ឧបករណ៍ស្តាប់" អាចធ្វើអោយកុមារខ្លះយល់នូវពាក្យបានល្អ ហើយអាចធ្វើអោយមានភាពខុសប្លែកគ្នាក្នុងការរៀនស្តាប់ និងនិយាយ។ ចំពោះកុមារខ្លះទៀតឧបករណ៍ផ្សេងៗ ពួកគេអាចយល់ពីសំលេង(ដែលជួយ) ប៉ុន្តែមិនអាចជួយពួកគេប្រាប់នូវពាក្យខុសគ្នាទាំងនោះបានទេ។ ប្រសិនបើវាកើតឡើង កុមារនឹងទទួលបានូវផលប្រយោជន៏ច្រើនពីឧបករណ៍ស្តាប់ វាអាចជួយកុមារបានទាន់ពេលវេលាសំរាប់កុមារអាយុ ១ ឬ ២ឆ្នាំ។

ឧបករណ៍សាមញ្ញគឺរាងបាតដៃដាក់ក្រោយត្រចៀក។



ល្អជាងនេះ គឺខ្លុយដាក់ត្រ-ចៀក អ្នកអាចធ្វើវាពីស្នែងគោ ក្តារក្រាស ឬកំប៉ុង ។



ឧបករណ៍ល្អ(ចំពោះកុមារខ្លះ) គឺ "**ឧបករណ៍ស្តាប់ដែលមានថ្ម**"។ ប៉ុន្តែជាធម្មតាមានតំលៃថ្លៃ។ ចំពោះលទ្ធផលល្អវាគួរតែត្រូវបានដាក់ដោយអ្នកជំនាញដែលមានការបណ្តុះបណ្តាល ជាពិសេសក្រោយពេល ការស្តាប់របស់កុមារមានការធ្វើតេស្ត យ៉ាងត្រឹមត្រូវ។






បំណែកនេះត្រូវនឹងទងត្រចៀក(ល្អប្រសិនបើចាក់ពុម្ភត្រូវតាមកុមារម្នាក់)។ នៅពេលដែលកុមារធំឡើងវាត្រូវតែប្តូរអោយបានទៀងទាត់។

> ***ចូរប្រយ័ត្ន*** : ប្រសិនបើកុមារទទួលបានឧបករណ៍ស្តាប់ ត្រូវធានានូវការសាកសួរអំពីការណែនាំដើម្បីជួយសំអាតអោយស្អួតនិងអោយមានដំណើរការល្អ។ ធានាថាអ្នកបានដាក់ថ្មបន្ថែមហើយដឹងអំពីការ រកថ្មមកដាក់បន្ថែមទៀត ។

- កុមារតូចដែលមានបញ្ហាត្រចៀក ជួនកាលគេត្រូវបានជួយអោយស្តាប់យ៉ាងយកចិត្តទុកដាក់ និងរៀនអំពីភាពខុសគ្នានៃសំលេងៈ ធ្វើអោយសំលេងខុសគ្នា ហើយលើកទឹកចិត្តដល់កុមារអោយចេះកត់ត្រា។ នៅពេលសត្វលាស្រែក ឬទារកយំ និយាយបានច្បាស់ និងឮៗៈ "ចូរស្តាប់សត្វលា" ឬ "តើនេះជាអ្វី "ប្រសិនបើកុមារឆ្លើយ ឬចង្អុលចំកន្លែងត្រូវសរសើរគេ។






អោយកុមារចេះប្រើសំលេងខុសគ្នា វាយខ្ទះ គោះស្គរ គោះកណ្តឹង និងផ្សេងៗ។ សូមពិនិត្យបើគេអាចធ្វើចលនា ឬរាំតាមចង្វាក់ភ្លេងឬស្គរ ។

និយាយទៅកាន់គេអោយបានច្រើន ច្រៀងជាមួយគ្នា ប្រាប់កុមារនូវផ្នែកផ្សេងៗនៃ រូបរាងកាយ និងវត្ថុផ្សេងនៃរូបរាងកាយ និងវត្ថុផ្សេងៗ។ អោយកុមារចេះស្ទាប ឬចង្អុល។ លើកសរសើរគេនៅពេលគេធ្វើអ្វីមួយ ធ្វើពិសោធន៏រកអោយឃើញនូវអ្វី ដែលត្រូវដាក់ជិតត្រចៀកនាង។ សំលេងកំរិតចំនួនដែលគេនិយាយ អោយគេចេះផ្តោតអារម្មណ៍ ហើយថាម្តងទៀតនូវពាក្យទាំងនោះ។ បន្ទាប់មកចូរព្យាយាមនិយាយអោយជិត ឬខ្លាំងល្មម។ និយាយអោយច្បាស់ប៉ុន្តែកុំស្រែកដាក់ត្រចៀក។

## វិធីផ្សេងៗដើម្បីជួយកុមារក្នុងការទំនាក់ទំនង

ទំនាក់ទំនងដោយបង្ហាញ




ជួយក្នុងការស្តាប់ និង និយាយ




ការធ្វើបបូរមាត់អាន




ទំនាក់ទំនងតាមរូបភាព និងចង្អុល



អានអក្សរដោយដៃ




សំរាប់ការអានអក្សរអង់គ្លេសមើលទំព័រ២៧៣

ការអាន និងសរសេរ




ភាសាសញ្ញា




### ការប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់

ការប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់ (ការប្រាស្រ័យទាក់ទងដោយប្រើមាត់) គឺតួបផ្សំក្នុងការជួយកុមារអោយចេះប្រើការស្តាប់ ដែលមានកំណត់របស់គេអោយបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបាន និងការអានបបូរមាត់និងការរៀននិយាយ។ ក្នុងប្រទេសភាគច្រើន សាលារៀនសំរាប់កុមារគថ្លង់ បង្រៀនអោយកុមារចេះប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់ តែងតែធ្វើទៅបានល្អសំរាប់កុមារដែលអាចស្តាប់បាន សំលេងខុសគ្នានៃពាក្យច្រើន ឬសំរាប់កុមារដែលក្លាយទៅជាកុមារថ្លង់ ក្រោយពេលដែលគេរៀននិយាយ។

### ការប្រាស្រ័យទាក់ទងចំរុះ

ការប្រាស្រ័យទាក់ទងចំរុះគឺជាវិធីទំនាក់ទំនងមួយដែលលើកទឹកចិត្តកុមារអោយចេះរៀន និងចេះប្រើនូវវិធីផ្សេងៗ ដែលល្អសំរាប់កុមារនៅតាមសហគមន៍ណាមួយរបស់គេ។ វិធីនេះរួមមានដូចខាងក្រោម :

- កាយវិការកុមារ
- ភាសាសញ្ញា
- ការគូរ ការអាន និង ការសរសេរ
- ការប្រកបម្រាមដៃ
- ទោះកុមារមានបញ្ហាក្នុងការស្តាប់យ៉ាងណាក៏ដោយ ចាំបាច់ត្រូវអភិវឌ្ឍន៏កុមារក្នុងការអានបបូរមាត់ និងការនិយាយស្តី។

***អត្ថប្រយោជន៏*** "ការប្រាស្រ័យទាក់ទងចំរុះ"ជាពាក្យមួយដែលយើងប្រើ " ប៉ុន្តែមិនមែនមានន័យថាវិធីទាំងអស់ខាងលើ អាចយកទៅប្រើសំរាប់គ្រប់កុមារទាំងអស់នោះទេ។ មានន័យថាយើងព្យាយាមប្រើគ្រប់វិធីទាំងអស់ដើម្បីអាចជួយដល់កុមារបាន។ បន្ទាប់មកយើងប្រើវិធីណាក៏បានដើម្បីជាទុនក្នុងការជួយកុមារ អោយធ្វើការប្រាស្រ័យទាក់ទងអោយបានស្រួលឆាប់ និងពេញលេញដែលអាចធ្វើទៅបានជាមួយក្រុមគ្រួសារនិងសហគមន៏។ វាជាវិធីមួយដែលមានលក្ខណៈស្និទ្ធស្នាល បត់បែនបាន និងសំរួលទៅតាមតំរូវការរបស់កុមារផ្ទាល់ និងសហគមន៏។

**ចូរប្រយ័ត្ន :  សូមចាំនូវកម្មវិធីដែលបង្រៀនសំរាប់វិធីប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់តែមួយគត់**

នៅក្នុងបណ្តាប្រទេសជាច្រើនសាលារៀនកុមារគថ្លង់  នៅតែព្យាយាមធ្វើយ៉ាងណាអោយកុមារគ្រប់រូប  អាចរៀនដោយវិធីប្រាស្រ័យទាក់ទងដោយមាត់ផ្ទាល់។ (ការអានបបូរមាត់  និងការនិយាយចេញជាពាក្យ)  លទ្ធផលបង្ហាញនូវភាពអវិជ្ជមាន  ឬគុណវិបត្តិដ៏ធំ។  ជាពិសេសចំពោះកុមារគថ្លង់ពីកំណើត។   ការអានបបូរមាត់ផ្តល់នូវការលំបាកច្រើនគួរសមដែរ។ អ្នកអានបបូរមាត់ដ៏ប៉ិនប្រសប់ អាចកាត់យល់ត្រឹមតែពាក្យអង់គ្លេសពី ៤០% ទៅ ៥០%ប៉ុណ្ណោះ។  ហើយក្រៅពីពាក្យទាំងនេះគេទាយតែម្តង។  ជាឧទាហរណ៏ " ម៉ាក់ "  និង "ប៉ា " មើលទៅចលនាបបូរមាត់ស្រដៀងគ្នាខ្លាំងណាស់។  ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏កុមាររៀនអានបបូរមាត់  និងនិយាយបានខ្លះៗ   ប៉ុន្តែជាទូទៅពាក្យទាំងអស់ គឺមិនច្បាស់ ឬសូរសំលេងប្លែកពីគេ។ ជាលទ្ធផលនៅពេលកុមារពេញវ័យធំឡើង គេមិនចូលចិត្តនិយាយទេ។

បញ្ហាដ៏ធំនៃការបង្រៀនកុមារអោយចេះធ្វើការប្រាស្រ័យទាក់ទងដោយមាត់ផ្ទាល់   គឺធ្វើការអភិវឌ្ឍន៏ទាំងភាសាទាក់ទង   របស់កុមារមានការយឺតយ៉ាវ  ក្នុងអំឡុងពេលកុមារមានអាយុដែលត្រូវរៀនទាំងភាសាបានយ៉ាងឆាប់រហ័សនោះ។ ( អាយុពី ១ឆ្នាំ ទៅ ៧ឆ្នាំ)  កុមារថ្លង់តែងតែរៀនអានបបូរមាត់  និងនិយាយបានតែ ៥ពាក្យ  ទៅ១០ ពាក្យនៅពេលគេអាយុ ៥ ឬ ៦ឆ្នាំ  ។ នៅពេលកុមារអាយុប៉ុណ្ណេះ កុមារដូចគ្នានេះអាចរៀនបានភាសាសញ្ញា ២០០០ ពាក្យបានយ៉ាងងាយស្រួល ដូចកុមារដែលស្តាប់ឮដែរ  ។

ការសិក្សាបានបង្ហាញថាកុមារគថ្លង់ដែលរៀនប្រើកាយវិការ      និងភាសាសញ្ញាអាចធ្វើការបាស្រ័យទាក់ទងបានស្រួលឡើងៗ      និងប្រសិនបើកុមារដែលគេបង្រៀនអោយចេះធ្វើការប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់។      ការរៀនភាសាសញ្ញា      និងទំរង់នៃការប្រាស្រ័យទាក់ទងដទៃទៀត  គឺប្រាកដណាស់ធ្វើអោយកុមាររៀននិយាយ  និងអានបបូរមាត់បានយ៉ាងស្រួល។  **មូលហេតុទាំងនេះ** :  អ្នកជំនាញ  និងអង្គការមនុស្សថ្លង់ជាច្រើនបានផ្តល់យោបល់ថា  "  ការបង្រៀនកុមារ   ថ្លង់ភាគច្រើនគឺរួមផ្សំរវាងវិធីប្រាស្រ័យទាក់ទង  រួមទាំងទំរង់នៃការប្រាស្រ័យទាក់ទងដទៃទៀត។

"  ការប្រាស្រ័យទាក់ទងចំរុះ  "  មិនមែនជាវិធីមួយថ្មីទេ   នៅតាមស្រុកភូមិក្នុងប្រទេសជាច្រើននៅលើពិភពលោក   ។  មនុស្សថ្លង់និងមនុស្សស្តាប់ឮអាចរកឃើញនូវវិធីស្រមើស្រមៃ   និងប្រសិទ្ធិភាពខ្ពស់ក្នុងការនិយាយទៅកាន់ទៅវិញទៅមក។   ពួកគេបានរិះរកនូវវិធីដូចជាសញ្ញាប្រអប់ដៃ  វត្ថុផ្សេងៗ  ការចលនាមុខ  រូបភាព  និងសូរសំលេង  ឬពាក្យ  រូបភាព  និងសូរសំលេង  ឬពាក្យជាក់លាក់ណាមួយ។  ជាលទ្ធផលមនុស្សថ្លង់ តែងតែគ្រប់គ្រងបានល្អនៅក្នុងសហគមន៏។ ពួកគេអាច "និយាយ" និងកាត់យល់បានច្រើន។ ( សូមមើលទំព័រ ១០០) ។

យើងស្គាល់ក្រុមគ្រួសារក្នុងភូមិ   ដូចនេះដែរដែលនាំអោយកុមារថ្លង់ទៅរកទីផ្សារដើម្បីអោយ"   អ្នកបង្ហាត់និយាយ"   ពិនិត្យមើល។ ជាទូទៅឪពុកម្តាយ  និងកូនរបស់ពួកគាត់បានចាប់ផ្តើមស្រេចនូវក្នុងការប្រាស្រ័យទាក់ទងជាមួយគ្នាដោយប្រើសញ្ញាក្នុងស្រុក  និងសញ្ញាដែលកើតដោយពួកគេផ្ទាល់។  កុមារមានការសប្បាយរីករាយហើយរៀនបានលទ្ធផលល្អ។  ប៉ុន្តែអ្នកបង្ហាត់បានប្រាប់ឪពុកម្តាយវិញថា    "ពួកគាត់បានធ្វើខុសហើយ"    ពួកគេបានប្រាប់ថា    ពួកគាត់មិនគួរអោយកុមារប្រើសញ្ញា    ពីព្រោះប្រសិនបើ    កុមារទំលាប់ប្រើសញ្ញាវានឹងមិនចេះនិយាយទេ។ ពួកគេបាននិយាយថា កុមារគួរត្រូវទទួល  " កម្មវិធីអប់រំពិសេស  "  និងបង្ហាត់ពី "ការប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់  " ប៉ុន្តែចាប់តាំងពីមានកម្មវិធីប្រភេទនេះ នៅក្នុងតែទីក្រុង( ហើយតែងតែមានបញ្ជីឈ្មោះ បំរុងរយៈពេល ៣ ឆ្នាំ) ។ ឪពុកម្តាយបានយកកូនត្រឡប់ទៅផ្ទះវិញ    ហើយព្យាយាមធ្វើតាមការណែនាំរបស់អ្នកបង្ហាត់និយាយ     ដោយពួកគេមិនគួរប្រើសញ្ញាជាមួយកូនរបស់គេទេ     ហើយដាក់ទណ្ឌកម្មគេនៅពេលគេប្រើ។ ជាលទ្ធផលទាំងឪពុកម្តាយ  និងកុមារ  គិតថាមានការស្មុគស្មាញ  ជាកំហុសខឹងសម្បា  និងឈឺចាប់។  ការរៀនរបស់កុមារ    និងការអភិវឌ្ឍន៏សង្គម    គឺដើរថយក្រោយវិញ។   ឱកាសនៃការរៀនសូត្ររបស់កុមារ    គឺមានតិចណាស់    ព្រោះអ្នករាល់គ្នាសប្បាយទៅនឹងការប្រើក្នុងប្រព័ន្ធស្រុកភូមិ  ។

ជាសំណាងល្អ   ក្រុមគ្រួសារទាំងនេះភាគច្រើនបានយល់ឃើញថា   ពួកគេមិនអាចគ្រប់គ្រងបានដោយមិនមានភាសាសញ្ញា   ហើយបន្ទាប់មកត្រឡប់ទៅទទួលយក  "  ការប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់  "  នៅក្នុងប្រទេសអភិវឌ្ឍន៏  អ្នកអប់រំពិសេសជាច្រើន  និងអ្នកបង្ហាត់និយាយ   បានចាប់ផ្តើមទទួលយក   "   ការប្រាស្រ័យទាក់ទងចំរុះ   "។  ពួកគេបានផ្លាស់ប្តូរវិធីបែបនោះខ្លះៗ  ដោយសារមនុស្សថ្លង់បានរៀបចំ  និងទាមទារអោយមាន។  មនុស្សពិការនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៏រួមទាំងមនុស្សថ្លង់  និងក្រុមគ្រួសាររបស់គេចាំបាច់ត្រូវជួយអ្នកឯកទេសអោយចេះស្តាប់នូវ     អ្វីដែលពួកគេនិយាយ     ហើយឆ្លើយតបទៅនឹងសេចក្តីត្រូវការទៅនឹងវិធីមួយដ៏ជាក់លាក់     និងត្រឹមត្រូវ  ។

## វិធីជួយកុមារអោយចេះធ្វើការប្រាស្រ័យទាក់ទងចំរុះ

- ទីកន្លែងសិក្សាគួរតែមានពន្លឺគ្រប់គ្រាន់ ធ្វើដូចនេះកុមារអាចឃើញ ដៃ ទឹកមុខ និងបបូរមាត់របស់អ្នក។
- មើលមុខអោយចំមុខកុមារ និងធ្វើអោយប្រាកដកុមារមើលចំមុខអ្នកវិញដែរ ។
- និយាយទៅកាន់កុមារអោយបានច្រើន ប្រសិនបើកុមារមិនអាចកាត់យល់និយាយបណ្តើរ ប្រើដៃ ទឹកមុខ បបូរមាត់បណ្តើរហើយព្យាយាមអោយគេមើលយ៉ាងយកចិត្តទុកដាក់។
- និយាយអោយបានច្បាស់ល្អប៉ុន្តែពុំចាំបាច់ស្រែកដាក់កុមារឡើយ ហើយចលនាមាត់ និងបបូរមាត់ត្រូវស៊ីគ្នាផងដែរ។ ការធ្វើដូចនេះអាចជួយកុមារអោយរៀនសំគាល់នូវសូរនិយាយតាមធម្មតា។




- ចូរចេះអត់ធ្មត់ និងធ្វើអ្វីមួយសារចុះសារឡើងអោយបានញឹកញាប់ ។
- ចូរធ្វើអោយប្រាកដថា អ្នកអោយគេដឹងនូវការសប្បាយរីករាយរបស់អ្នកនៅពេលនាងនិយាយអ្វីមួយ ឬធ្វើអ្វីមួយបានល្អ។
- លើកទឹកចិត្តអោយគេនិយាយឬបញ្ចេញអ្វីដែលគេអាចធ្វើបាន។ធ្វើបែបនេះជួយកុមារអោយចេះពង្រឹងសង្កត់សំលេងអោយទៅតាមសំដីសមស្រប។
- គួរតែមានតុក្កតា និងវត្ថុផ្សេងៗទៀតដើម្បីយកមកប្រើក្នុងការជួយអោយគេរៀនសាលាសញ្ញា និងពាក្យផ្សេងៗ។
- អោយមានការរៀនធ្វើការប្រាស្រ័យទាក់ទងគ្នាប្រកបដោយភាពសប្បាយរីករាយ អោយកុមារចូលរួមក្នុងការលេងល្បែងកំសាន្តផ្សេងៗ " **តុក្កតា ស៊ីម៉ុន ចេះនិយាយ**" ដែលអាចជួយអោយកុមារចេះប្រើភ្នែកនិងត្រចៀកព្រមទាំងកាយវិការ ហើយចេះថតចំលងពីគ្នាទៅវិញទៅមក (សូមមើលទំព័រ ១៣៤) ។
- លេងល្បែងកំសាន្តដែលជួយពត់សាច់ដុំបបូរមាត់ អណ្តាត និងមាត់របស់កុមារ។ ចំពោះកុមារថ្លង់ សាច់ដុំ ទាំងនេះខ្សោយ។ នេះមិនគ្រាន់តែធ្វើអោយការនិយាយស្តីមានការលំបាកប៉ុណ្ណោះទេ ប៉ុន្តែវាអាចធ្វើអោយមុខមាត់របស់កុមារស្លេកស្លាំង ឬគេមានអារម្មណ៍ភ្លឹកៗ។ ចំពោះសកម្មភាពពង្រឹង គ្រប់គ្រងមាត់ និងបបូរមាត់ (សូមមើលនៅទំព័រ ១៣២-១៣៣ ) ។
- ធ្វើតារាងពាក្យដែលកុមារដទៃទៀតតែងតែប្រើដែលមានអាយុស្រករគ្នា ហើយនូវអ្វីដែលអ្នកចង់អោយកុមារចេះ :

| | | | | |
|---|---|---|---|---|
| • ពាក្យសំខាន់ៗក្នុងការរៀនលេង ល្បែង ផ្សេងៗ: ចាំស/បាទ , ទេ, អរគុណ, អ្នក, អ្វីខ្លះ, សូម អញ្ជើញ, ធ្វើ, មិនធ្វើ, ចូលចិត្ត , ចង់ | • វត្ថុផ្សេងសាមញ្ញគួរអោយចាប់អារម្មណ៍ សរីរាង្គមនុស្ស សត្វ ពាហនៈ សំលៀក បំពាក់ម្ហូបអាហារ ។ | • ពាក្យសំរាប់សកម្មភាព ទៅ មក ហូប ផឹក គេង ផ្តល់អោយ ដាក់ ឃើញ ស្តាប់ បោកគក់ ដើរ រត់ លេង Pee | • មនុស្ស: អ្នក ខ្ញុំ គាត់ វា យើង ពួកគេ ម៉ាម៉ា ប៉ាប៉ា សុខ ខេង និងសមាជិកគ្រួសារផ្សេងៗទៀត ។ | • ពាក្យសំរាប់ពិពណ៌នាតូច ធំ លើ ក្រោម ធាត់ ស្គម ស្អាក្រក់ ក្តៅ ត្រជាក់ ថ្ងៃ យប់ ។ |

ចូរចាប់ផ្តើមដំបូងនូវតារាងពាក្យខ្លីមួយ ហើយបន្ទាប់មកបន្ថែមអោយបានច្រើនទៀត។ ចូរប្រើអោយបានញឹកញាប់នៅក្នុងសកម្មភាពប្រចាំថ្ងៃដូចជា (ការបញ្ចុកចំណី,ការងូតទឹក,ការស្លៀកពាក់ និងការលេង ) ។ អោយក្រុមគ្រួសារទាំងមូលចេះនូវពាក្យលើតារាង និងពីរបៀបខ្លះនៃការធ្វើសញ្ញាសំរាប់អោយគេបានយល់។ លើកទឹកចិត្តអោយមនុស្សរាល់គ្នាចេះប្រើពាក្យ និងសញ្ញារួមគ្នាក្នុងពេលតែមួយ។ ប៉ុន្តែមិនមែនសំរាប់តែនៅពេលដែលអ្នកនិយាយជាមួយកុមារនោះទេ។ ទោះបីជាអ្នកនិយាយគ្នាជាមួយមនុស្សដទៃទៀតក៏ដោយ និងរួមទាំងវត្ថុអ្វីដែលកុមារអាចធ្វើនៅផ្ទះបាន។ វិធីនេះកុមារនឹងរៀនចេះនូវភាសាតាមរយៈការលេង ការមើល និងការស្តាប់ (អោយបានច្រើនតាមដែលអាចធ្វើទៅបាន )។ ហើយក្រោយមក ដោយចំលងតាម ដែលជាវិធីដ៏សំខាន់អោយកុមាររៀនភាសាបាន។

- នៅពេលដែលកុមារមានវ័យធំឡើងជួយអោយគេដឹងខ្លះៗពីអក្សរ និងពាក្យដែលបានសរសេរ។ អ្នកអាចសរសេរទីមួយ ឬដាក់ឈ្មោះអោយវត្ថុដែលមាននៅជុំវិញផ្ទះ។ ឬក៏ធ្វើជារូបភាពដែលមានដាក់ឈ្មោះដូចជា ធំ អក្សរច្បាស់ ឬ ក៏ធ្វើជាកាតអក្សរពីរ ធ្វើដូចនេះកុមារនិង អាចផ្គូរផ្គងរូបភាព និងពាក្យ ។ ធ្វើបែបនេះនឹងជួយអោយកុមារកាត់យល់នូវសញ្ញាប្រអប់ដៃដែលស៊ីគ្នានឹងអក្សរទាំងនោះ។ វានឹងរៀបរយអ្នកក្នុងការរៀនអក្ខរក្រមតាមការសរសេរនិងសញ្ញាហើយវាជាប្រយោជន៍ក្នុងការរៀនអាន និងសរសេរ។



## ភាសាសញ្ញា

នៅតាមភូមិ និងសហគមន៍មនុស្សច្រើនប្រើ និងកាត់យល់កាយវិការ ឬសញ្ញាដែលធ្វើដោយប្រអប់ដៃ។ សញ្ញាភាគច្រើន " សណ្ឋានសាមញ្ញ " ឬតាងជាតំណាងវត្ថុអ្វីមួយ។ ល្បែងខ្លះដែលកុមារលេងគឺប្រើសញ្ញាប្រអប់ដៃ។ ឧទាហរណ៍ :

នេះព្រះវិហារ នេះកំពូលស្រួច បើកទ្វារ ហើយសូមមើល



មនុស្សម្នា



នៅពេលក្រុមគ្រួសារមានកូនថ្លង់ម្នាក់ពួកគេចាប់ផ្តើមប្រើសញ្ញាក្នុងស្រុក និងបង្កើតសញ្ញាថ្មីដោយខ្លួនគេផ្ទាល់ផងដែរ។ ឧទាហរណ៍: នៅឯមណ្ឌលស្តារលទ្ធភាពផលិតកម្មក្នុងភូមិ ក្នុងប្រទេសម៉ិចស៊ិកូគ្រួសារមួយបានជិះរទេះសេះមកដល់មណ្ឌលដែលមានកូនប្រុសថ្លង់ម្នាក់អាយុ៦ឆ្នាំ។ ក្មេងប្រុសមានការភ័យតក់ស្លុតហើយចង់ត្រឡប់ទៅផ្ទះវិញ។ ដូច្នេះគេបានទាញដៃអាវរបស់ឪពុកគេ ហើយ បញ្ចេញជាសំលេង និងសញ្ញាដូចជា :

អ្នក និង ខ្ញុំ ទៅផ្ទះវិញ ដោយជិះរទេះសេះ សូមអង្វរ



គ្រួសារនេះបានចាប់ផ្តើមយល់ដឹងអំពី ភាសាសញ្ញាទាំងនេះដោយពុំមានការបង្ហាត់បង្រៀនឡើយ។ ក្មេងប្រុសបានបង្កើតជាមួយកូនថ្លង់របស់គេ គឺតែងតែមិនពេញលេញ។ ការប្រាស្រ័យទាក់ទងគឺនៅតែមានការលំបាក។ ទោះជាយ៉ាងណាក៏ដោយមនុស្សទូទៅបានសហការគ្នា ដើម្បីបង្កើតភាសាសញ្ញាដែលមានលក្ខណៈពេញលេញ និងត្រឹមត្រូវ។ មានភាសាសញ្ញាខុសប្លែកពីគ្នារាប់ពាន់ ប៉ុន្តែមានភាសាសញ្ញាបីប្រភេទដែលសំខាន់រួមមាន:




- ភាសាសញ្ញាជាតិ និងតំបន់ប្រទេសជាច្រើននៅលើពិភពលោក មនុស្សថ្លង់បានបង្កើតភាសាសញ្ញាដោយខ្លួនឯងធ្វើដូចនេះពួកអ្នកអាច រៀនធ្វើការប្រាស្រ័យទាក់ទងបានល្អនិងបានលឿនដូចមនុស្សធម្មតាដែរ។ សញ្ញានៃភាពខុសប្លែកពីគ្នាជាច្រើនជាតំណាងអោយវត្ថុសកម្មភាពនិងគំនិតខុសៗពីគ្នា។ វចនាសម្ព័ន្ធ (វេយ្យាករណ៍) នៃភាសាសញ្ញាទាំងនេះ គឺខុសប្លែកពីគ្នារវាងភាសានិយាយហើយធម្មតាពិបាករៀនណាស់។ ភាសាទាំងនេះមានការទទួលចំណាប់អារម្មណ៍ខ្ពស់ពីមនុស្សថ្លង់ពីកំណើត។ ឧទាហរណ៍:ភាសាសញ្ញាអាមេរិកាំង(ASL) ដែលត្រូវបានគេប្រើនៅក្នុងសហរដ្ឋអាមេរិក កាណាដា និងរួមទាំងភាសាសញ្ញាម៉ិចស៊ិកូ ។
- ភាសាសញ្ញាផ្អែកលើភាសានិយាយ: ភាសាទាំងនេះមានវចនាសម្ព័ន្ធ និងវេយ្យាករណ៍ដូចគ្នាទៅនឹងភាសានិយាយក្នុងស្រុក។ ភាសាទាំងនេះមានការងាយស្រួលអោយមនុស្សធម្មតារៀន និងមនុស្សមួយចំនួនដែលទើបពិការថ្លង់កាត់យល់ក្រោយពីពួកគេបានរៀននិយាយ។ ជួនកាលពួកគេប្រើអក្សរដំបូង (ការប្រកបម្រាមដៃ) នៃពាក្យមួយដែលជាផ្អែកនៃភាសាសញ្ញា។ វាមានការលំបាករៀនចំពោះកុមារដែលមិនអាចអានបាន ប៉ុន្តែវាអាចធ្វើការរៀនអានបានងាយស្រួលជាងនេះ និងប្រកបដោយភាពសប្បាយរីករាយ។ ឧទាហរណ៍ : ភាសាសញ្ញាអង់គ្លេស និងអេស្ប៉ាញ ។




- ការប្រកបម្រាមដៃ :ពាក្យនិមួយៗត្រូវបានប្រកបចេញមកជាមួយការប្រើសញ្ញាប្រអប់ដៃដែលជាតំណាងអោយអក្ខរក្រមក្នុងស្រុក។ វិធីនេះគឺសំដៅទៅលើ "ការសរសេរលើខ្យល់" ដែលយឺតយ៉ាវ ប៉ុន្តែច្បាស់លាស់វាមានលក្ខណៈងាយស្រួលចំពោះមនុស្សរៀនដែលពួកគាត់អាចអានអក្សរ និងសរសេររួចហើយ។ ចំពោះភាសាអង់គ្លេស ជនជាតិអង់គ្លេសប្រើប្រព័ន្ធប្រអប់ដៃពីរ ហើយជនជាតិអាមេរិកាំងប្រើប្រព័ន្ធប្រអប់ ដៃមួយ។ ព្យាយាមរៀនពីប្រព័ន្ធដែលត្រូវបានប្រើជាទូទៅក្នុងប្រទេសអ្នក។




មនុស្សថ្លង់ភាគច្រើនប្រើរួមគ្នានូវប្រព័ន្ធទាំងបី ។ ចំពោះមនុស្សថ្លង់ដទៃទៀតពួកគេច្រើនតែប្រើប្រព័ន្ធទី១ ជាមួយមនុស្សធម្មតា ឬអ្នកបកប្រែ ។ អ្វីដែលពួកគេប្រើគឺប្រព័ន្ធទី២ ច្រើនជាងការប្រកបម្រាមដៃគឺពិបាកសំគាល់ពាក្យ ។ នៅពេល "និយាយ" ទៅកាន់អ្នកដែលមិនចេះភាសាសញ្ញា គឺពួកគេចេះសរសេរនូវអ្វីដែលពួកគេចង់និយាយ ឬប្រើក្តារអក្សរ ។

## រៀនប្រើសញ្ញា

ប្រសិនបើអាច ទំនាក់ទំនងជាមួយសហគមន៏មនុស្សថ្លង់ក្នុងប្រទេសរបស់អ្នក ហើយពិនិត្យថាអ្នកអាច ទទួលសៀវភៅណែនាំមួយជាភាសាសញ្ញាតាមតំបន់ ឬភាសានិយាយរបស់គាត់ ។ ប្រសិនបើមិនអាចអ្នកប្រើសញ្ញានិងកាយវិការក្នុងស្រុក ហើយបង្កើតសញ្ញាអោយបានច្រើនដោយខ្លួនឯង ។

នៅទំព័រខាងមុខយើងបានផ្តល់នូវគំនិត យោបល់ជាច្រើនធ្វើជាសញ្ញា ឧទាហរណ៍សំរាប់តែភាសាសាមញ្ញ១ ។ ហើយភាសាភាគច្រើនជាភាសាសញ្ញាអាមេរិកាំង ។ អ្នកនឹងចង់ផ្លាស់ប្តូរសញ្ញាទាំងនេះ អោយស្របតាម កាយវិការ វប្បធម៌ និងភាសាតាមតំបន់ ។ នៅទីនេះជាគំនិតខ្លះ១ :

- ជ្រើសរើសសញ្ញាដែលមិនបង្កលក្ខណៈលំបាកដល់មនុស្សទូទៅ( មនុស្សថ្លង់បានជួបនូវការលំបាកជាច្រើន) ទីនេះជាឧទាហរណ៏ខ្លះ១ដូចជា :

| | | |
|---|---|---|
| នៅសហរដ្ឋអាមេរិកការចង្អុលម្រាមដៃត្រូវបានប្រើបញ្ជាក់ពីមនុស្សផ្សេង១ ខ្ញុំ អ្នក គាត់ ពួកគេ  | នៅក្នុងប្រទេសខ្លះ ការចង្អុលម្រាមដៃ មិនមានលក្ខណៈគួរសមទេ ដូចនេះ គេប្រើដៃលាតសន្ធឹង  | ក្នុងទីកន្លែងដទៃទៀត គ្រាន់តែការចង្អុលដោយប្រអប់ដៃលាតសន្ធឹងមិនគួរសមទេ ។ ហើយមនុស្សបួញមាត់ប្រាប់  |
| អក្ខរក្រមសញ្ញាត្រូវបានគេប្រើនៅសហរដ្ឋអាមេរិកនិងកាណាដាចំពោះអក្សរ "T " ធ្វើដូចនេះ ។ ទោះជាយ៉ាងណាក្នុងប្រទេសជាច្រើនកាយវិការនេះគឺគ្រោះថ្នាក់បំផុត ។  | ដូច្នេះ ក្នុងសៀវភៅនេះ យើងអាចប្រើសញ្ញា " T " ចេញពីភាសាសញ្ញាអេស្បាញ និងដង់នីស ។  | ដើម្បីជៀសវាងការភាន់ច្រលំ ឧទាហរណ៏សញ្ញា "នៅទីណា"ក្នុងសហរដ្ឋអាមេរិកគឺជាកាយវិការដ៏សាមញ្ញបំផុត ។ ចំពោះពាក្យ" ទេ " ប្រើនៅប្រទេសម៉ិចស៊ិកូ ។  |

- ការប្រើសញ្ញាក្នុងស្រុកប្រសិនបើមនុស្សក្នុងតំបន់ជាច្រើនមានកាយវិការ ឬសញ្ញាសំរាប់អ្វីមួយដែលត្រូវប្រើជំនួសដោយភាសាសញ្ញាថ្មី ឬសញ្ញាបរទេស ។ ឧទាហរណ៏:

| | | |
|---|---|---|
| សញ្ញាអាមេរិកាំងដែលមានន័យថា " ទេ"  | ប្រទេសខ្លះប្រើសញ្ញាដូចនេះ ជា " ទេ "  | នៅស្យាម៉ាកាទេនិងមិនបានគេតែងតែនិយាយតាមលក្ខណះអវិជ្ជមានហើយកោរពុះមាត់ឬផ្អៀងក្បាលទៅម្ខាង  |

| | |
|---|---|
| នេះជាសញ្ញា "គេង " សំរាប់សញ្ញាអាមេរិកាំង  | នៅប្រទេសណេប៉ាល់ សញ្ញា " គេង "ជាភាសាសញ្ញា ។គេអាចកាត់យល់នៅគ្រប់ទីកន្លែង ។  |

- **ការប្រើទ្រង់ទ្រាយប្រអប់ដៃ  ឥរិយាបថ  ការចល័ត  និងទិសដៅ នៃការធ្វើសញ្ញាផ្សេងៗ**។ ការបញ្ចេញទឹកមុខជាការបន្ថែម អត្ថន័យ។ ឧទាហរណ៍  នេះជាសញ្ញា  " ម្ដាយ "




- ព្យាយាម**ធ្វើសញ្ញា  ដូចជា  វត្ថុ  ឬសកម្មភាព  ដែលតាងអោយ**។  ដើម្បីធ្វើវា  អ្នកអាចប្រើការផ្សំចូលគ្នានូវទ្រង់ទ្រាយ **ប្រអប់ដៃ** និង**ការចល័ត**។




- កែសំរួលខ្នាត និងកំរិតនៃសញ្ញា ដូចគ្នា ដែលពិពណ៌នាអំពីវត្ថុ និងសកម្មភាព និងការប្រើផ្ទុយគ្នា   ឧទាហរណ៍




សូមមើលសញ្ញាបន្ថែមទៀតនៅទំព័រ ៩៦

- រៀនសញ្ញាថ្មី ដោយការចង្អុលទៅកាន់វត្ថុ



- **គួបផ្សំសញ្ញា ដែលប្រើសំរាប់វត្ថុ និងសកម្មភាពផ្សេងៗ ដើម្បីធ្វើការប្រាស្រ័យទាក់ទងបញ្ចេញជាគំនិត ឬប្រយោគផ្សេងៗ**។ ការរៀបចំពាក្យមិនតំរូវអោយដូចគ្នាទៅនឹងភាសានិយាយនោះទេ ហើយអ្នកអាចយកពាក្យ " បន្ថែម " ចេញ ដូចជា " the " និង " a " ហើយពាក្យដូចជា " to " និង " from " ជានិច្ចគេយកវាចេញ ឬវាអាចត្រូវបានបញ្ជាក់ពីបំណងនៃអារម្មណ៍។







- សំរេចថាតើត្រូវប្រើ ឬមិនប្រើនូវតួអក្សរនៃអក្ខរក្រមដើម្បីបង្កើតនូវសញ្ញា។ នៅក្នុងភាសាសញ្ញាខ្លះតួអក្សរទីមួយនៃពាក្យនិយាយ(សរសេរ) ត្រូវបានប្រើជាសញ្ញា សំរាប់ពាក្យនោះ។ ដំបូងនេះនឹងមិនមានន័យអ្វីទេចំពោះកុមារដែលមិនអាចអាន និងវានឹងកាន់តែពិបាកទៅៗ។ ប៉ុន្តែវាអាចជួយរៀបចំអោយកុមាររៀនអាន និងប្រកបប្រាមដៃ។ ជាថ្មីម្តងទៀត ពាក្យត្រូវបានប្រើជាលក្ខណៈក្បួនខ្នាត រួមមានៈ




ប្រាកដថា សញ្ញាដែលផ្អែកលើតួអក្សរ ដែលស្របទៅតាមពាក្យក្នុងប្រទេសរបស់អ្នក។ ភាសាអេស្ប៉ាញ "ឪឡឹក" គឺ សញ្ញា " សានឌៀ " ហេតុដូច្នេះ ភាសាសញ្ញាអង់គ្លេសមិនមានន័យគ្រប់គ្រាន់ទេ។ ប៉ុន្តែ ភាសាសញ្ញាអេស្ប៉ាញ គឺៈ




- អ្នកអាចបង្កើតភាសាសញ្ញា សំរាប់ឈ្មោះមនុស្ស ដោយប្រើតួអក្សរទីមួយ នៃឈ្មោះពួកគេ និងដោយការបង្ហាញនូវអ្វីមួយដែលតាងអោយមនុស្សនោះ ឬប្រើទាំងពីរ






## តើត្រូវសួរសំណួរយ៉ាងដូចម្តេច?




### ឧទាហរណ៍សញ្ញាខ្លះ

សញ្ញាដែលបង្ហាញនេះ ត្រូវបានប្រើជាទូទៅនៅសហរដ្ឋអាមេរិក (សញ្ញាអាមេរិកាំង)។ សញ្ញាខ្លះយកមកពីប្រទេស ណេប៉ាល់ ស្បាម៉ាកា និងម៉ិចស៊ិកូ ដោយសារតែសញ្ញាទាំងនេះ មានលក្ខណៈងាយស្រួលយល់។ យើងបានជ្រើសរើសសញ្ញាពិពណ៌នាអំពីវត្ថុ និងសកម្មភាពដែលមានសារៈសំខាន់ដល់ការរៀនឆាប់ៗ និងល្បែងជាក្រុមដែលលេងជាមួយកុមារ។ យើងបានបញ្ចូលសញ្ញាទាំងនេះជាពិសេសការផ្តល់ជាគំនិតយោបល់។ ផ្លាស់ប្តូរនិងសំរួលសញ្ញាទាំងនេះអោយ បានប្រសើរដើម្បីសំរួលទៅតាមតំបន់និមួយៗ។

- សញ្ញា (→) ក្នុងគំនូរ គេបង្ហាញពីទិសដៅនៃចលនាដៃបង្កើតជាសញ្ញា
- សញ្ញាទឹករលក (~~~~) ត្រូវបានប្រើជាមួយសញ្ញា ដោយធ្វើជាការចាប់ដៃ និងម្រាមដៃ
- សញ្ញាចំនុចតូច (...) បង្ហាញនូវរាងរូវនៃសញ្ញា នៅពេលចាប់ផ្តើម
- សញ្ញាចំនុចខ្មៅ ត្រូវបានប្រើនូវអ្វីដែលជាទីបញ្ចប់

សំគាល់: សញ្ញាមួយចំនួនដែលបង្ហាញនៅទីនេះផ្អែកទៅលើតួអក្សរនៃអក្ខរក្រម (ឧទាហរណ៍វាប្រើតួអក្សរ "i" ហើយតួអក្សរ "W"។ ចូរផ្លាស់ប្តូរសញ្ញាទាំងនេះ ប្រសិនបើអ្នកនិយាយភាសាផ្សេង ឬប្រសិនបើអ្នកចង់ជៀសវាងការប្រើសញ្ញាដែលផ្អែកលើតួអក្សរ)។




ល្អ
អាក្រក់
រីករាយ
បារម្ភ
ស្អាត/ល្អ
ប្រលាក់ដី/គគ្រិច
ក្ដៅ
ត្រជាក់
តូច
ធំ
ក្រោម
លើ
កង្វក់
ស្អាត
ធាត់
ស្គម
ខ្សោយ
ខ្លាំង
ខាងក្នុង
ខាងក្រៅ
ក្រោម
ហត់នឿយ
ឈឺ
ខឹង
ឃ្លាន
ញ៉ាំ
ម្ហូបអាហារ
ស្រេកទឹក
ផឹកទឹក
ទឹក
ទឹកដោះគោ
សំល
នំប៉ុង
ចានគោម
ស្លាបព្រា
បន្ទប់ទឹក
ផ្ទះ
ភូមិ/សហគមន៍
/ទីក្រុង/ទីប្រជុំជន
សាលារៀន
លុយ
នៅសហរដ្ឋអាមេរិក
នៅប្រទេសណេប៉ាល់
នៅប្រទេសម៉ិចស៊ិកូ
ពិការភ្នែក
គថ្លង់
ឧបករណ៍ស្តាប់
ភ្លេច
ចងចាំ
យល់
ពណ៌ក្រហម
ពណ៌បៃតង
ពណ៌ខៀវ
ពណ៌លឿង
ពណ៌ខ្មៅ
ពណ៌ស


មក
ទៅ
ចាប់ផ្ដើម
ឈប់
ផ្ដល់អោយ
មាន(កម្មសិទ្ធ)
ចង់បាន
មិនចង់បាន
ឃើញ
មើល
ឮ
ស្ដាប់
និយាយ
ផលិត
ធ្វើការ
ប្រើ
លេង
ល្បែង
យក(កាន់)
នាំយក
ដាក់
ជួយ (ជំនួយ)
បង្រៀន
រៀន
ឈរ
ដេក
ដើរ
រត់
រអិល
ធ្លាក់
អង្គុយ
អង្គុយចោងហោង
ចូលចិត្ត
ស្រលាញ់
គូររូប
សរសេរ
មាន់
ពពែ
សេះ
គោ
ក្របី
ឆ្កែ
ថ្ងៃ
ពេលព្រឹក
ពេលរសៀល
ពេលយប់
ចាស/បាទ
ទេ
មួក
អាវ
ខោ
សំពត់
ស្រោមដៃ
ស្បែកជើង




រាបលេខ (ប្រពន្ធ១ក្នុងចំណោមប្រព័ន្ធជាច្រើន)




ព្យញ្ជនៈដោយសញ្ញាដៃម្ខាង (ប្រពន្ធអាមេរិកាំង)



## ជួយកុមារឱ្យរៀនធ្វើសំលេង និងនិយាយ

១. ប្រសិនបើកុមារព្ញទាំងអស់ ចូរលើកទឹកចិត្តកុមារឱ្យ **ចំណាំ និងស្តាប់សំលេងផ្សេងៗ** ដូចដែលបានពិភាក្សានៅទំព័រទី ៨៦ ។

២. ចូរលេងល្បែងកំសាន្ត និងធ្វើលំហាត់ប្រាណ ដើម្បីជួយកុមារឱ្យរៀន**ប្រើមាត់ អណ្តាត និងបបូរ** (ចូរមើលទំព័រ ១៣២ និង ១៣៣) ។ ចូរឱ្យកុមារសង្កត់បបូរមាត់ចូលគ្នា ហាក់ដូចនិយាយថា "មមម"  ធ្វើបបូររាងរង្វង់ដូចអក្សរ :អូ"  និងពន្លាមាត់ និងញញឹម ហាក់ដូចនិយាយថា" អេ"  ចូរមើល ក្រែងកុមារអាចយកអណ្តាតឱ្យប៉ះច្រមុះ ចង្ការ ថ្ពាល់របស់គេ ។ ចូរឱ្យកុមារផ្លុំពពុះសាប៊ូ ឬផ្លុំទៀនពន្លត់ ។ ចូរផ្តល់អាហារឱ្យគេទំពារនិងជញ្ជក់ ។





៣. ចូរលើកទឹកចិត្តកុមារឱ្យចាប់ផ្តើម**ធ្វើសំលេង** ។ ពាក្យ " មមម " ជាពាក្យល្អដើម្បីចាប់ផ្តើមធ្វើសំលេង ព្រោះវាងាយ ស្រួលធ្វើ ។ ប្រសិនបើចាំបាច់ចូរបង្ហាញកុមារពីវិធីដែលគេអាចទប់បបូររួមគ្នាដើម្បីធ្វើសំលេង ។ ចូរអង្គុយជិតគេ ដូចនេះកុមារអាចមើលឃើញ (និងស្តាប់លឺ?)និងចំលងតាមអ្នក ។ ជាធម្មតា សូរសំលេងដែលងាយរៀនមានអក្សរ ´ah`, ´ay', 'ee', 'aw', 'o', 'p', 'b', 't' និង 'd' (ចូររក្សាពាក្យពិបាកជាច្រើនដូចជា 'v', 'w' , 'j', 's' , 'n' , 'r' និងអក្សរ 'z' សំរាប់ពេលក្រោយ) ។




៤. ប្រសិនបើកុមារប្រើមាត់ និងបបូរមាត់របស់គេ ប៉ុន្តែមិនមែនជាសំលេងរបស់ គេទេ ចូរឱ្យគេទទួលអារម្មណ៍ "លឺសូររ៉ឺៗ" ឬរំញ័រនៅក្នុងបំពង់ករបស់គេ នៅពេលដែលអ្នកធ្វើសូរសំលេងផ្សេងៗគ្នា ។ ដើម្បីធ្វើឱ្យទទួល "អារម្មណ៍ " ពីពាក្យ ផ្សេងគ្នា អ្នកអាចដាក់ដៃរបស់កុមារនៅលើថ្ពាល់ បបូរ បំពង់ក និងទ្រូងរបស់អ្នក ។ រួចចូរឱ្យកុមារទទួលអារម្មណ៍ពី បំពង់ករបស់ខ្លួនឯង នៅពេលដែលគេព្យាយាមចំលងតាមអ្នក ។



៥. ចូរឱ្យកុមារទទួលអារម្មណ៍ និងប្រៀបធៀបចលនាខ្យល់ពីមុខមាត់របស់អ្នក និងមាត់របស់គេផងដែរ ដោយប្រើសូរ សំលេង ដូចជា 'ha', 'he', 'ho', 'm', 'p', 'b' និង 'f' ។ តាមវិធីដូចគ្នានេះ ចូរឱ្យកុមារទទួលអារម្មណ៍ថា ខ្យល់ធ្វើចលនានៅពេលដែលគេ "ញើសសំបោរ " ដោយបិទមាត់របស់គេ ។ ដោយប្រើវិធីនេះ ចូរព្យាយាមបង្រៀនសំលេងផ្សេងៗ ដូចជា 'n' និង 'l' ។

៦. ចាប់ផ្តើមបង្រៀនពាក្យដល់កុមារ ដោយប្រើសំលេងដែលគេកំពុងរៀន ។ ដំបូងបំបែកពាក្យជាសំលេងផ្សេងៗ ។ ដើម្បីនិយាយពាក្យ 'Ma' ដំបូងចូរឱ្យកុមារនិយាយ 'm' ដោយបិទបបូរមាត់ ។ បន្ទាប់មក 'ah' ដោយបើកបបូរមាត់ ។ បន្ទាប់មកទៀត និយាយពាក្យ 'mah' និងឱ្យកុមារព្យាយាមចំលងតាម ។



៧. នៅពេលដែលកុមាររៀនពាក្យ ចូរបង្រៀនគេពីអ្វីដែលអ្នកចង់និយាយ និងឱ្យគេប្រើពាក្យទាំងនេះ ។ ឧទាហរណ៍ បង្រៀន កុមារពីពាក្យ 'nose' ចូរឱ្យគេធ្វើសំលេង 'n', 'o', និង 's' ។ បន្ទាប់មក ឱ្យគេបញ្ចូលពាក្យរួមគ្នា ។ ចូរសុំកុមារស្ទាបច្រមុះនៅពេលដែលគេនិយាយពាក្យនោះ ។ ចូរឱ្យគេចំលងតាម ។ ចូរសរសើរគេ និងធ្វើវាឱ្យទៅជាល្បែង ។

៨. បន្តិចម្តងៗ ចូរជួយកុមាររៀនពាក្យជាច្រើន និងហាត់ប្រើពាក្យទាំងនោះតាមរយៈល្បែង និងសកម្មភាពប្រចាំថ្ងៃ ។ ចូរឱ្យគេរៀនឈ្មោះខ្លួនឯង និងឈ្មោះក្រុមគ្រួសារ និងមិត្តភ័ក្តិ ។ ចូរបង្កើតបញ្ជីពាក្យដូចដែលពន្យល់នៅលើទំព័រ ៨៩ ។ ប៉ុន្តែចូរកុំព្យាយាមធ្វើលឿនពេក ។ ចូរប្រើពេលដើម្បីជួយគេឱ្យនិយាយពីរ បីពាក្យឱ្យបានត្រឹមត្រូវច្បាស់លាស់ មុនពេលបន្តទៅទៀត ។

## ការអានបបូរមាត់

កុមារដែលបាត់បង់ការលឺសំលេងច្រើន ជារឿយៗ ពឹងផ្អែកដោយឡែកលើការអានបបូរមាត់ ដើម្បីយល់អ្វី ដែលអ្នកដ៏ទៃកំពុងនិយាយ ។ ប៉ុន្តែការអានបបូរមាត់ មិនមែនងាយរៀនឡើយ ។ ចូរកុំព្យាយាមប្រញាប់ឱ្យកុមារ ចេះ បើពុំនោះទេ គេ( និងអ្នក) អាចបង់ទឹកចិត្តដោយងាយ ។ **ចូរកុំចាប់ផ្តើមបង្រៀនការអានដោយប្រើបបូរមាត់ រហូតទាល់ តែកុមារមានវ័យ ៣ ឆ្នាំយ៉ាងតិច ។**




ចូរអង្គុយពីមុខកុមារនៅកន្លែងភ្លឺល្អ និងបង្ហាញគេពីអ្វីមួយ ដូចជាបាល់ ជាឧទាហរណ៏ ។ ចូរនិយាយពាក្យ "បាល់" ដោយធ្វើចលនាបបូរមាត់របស់អ្នកអោយបានច្បាស់ និងនិយាយយឺតៗ ។ ចូរឱ្យកុមារមើលឃើញបបូរមាត់របស់អ្នកធ្វើចលនា និងមើលមុខរបស់អ្នក ។ ចូរនិយាយច្រំដែលពីពាក្យដដែលជាច្រើនសារ ។



បន្ទាប់មកចូរអង្គុយជាមួយកុមារពីមុខកញ្ចក់ ដើម្បីឱ្យគេអាចមើលឃើញមុខរបស់អ្នកទាំងពីរ ។ ចូរនិយាយពាក្យ "បាល់" និងបន្ទាប់មកចូរឱ្យគេចំលងតាមអ្នក ដោយមើលបបូរមាត់ និងមុខរបស់អ្នកទាំងពីរនៅក្នុងកញ្ចក់ ។


អោយប្រាកដថា កុមារគឺកំពុងតែមើលមាត់អ្នក

តាមវិធីនេះ ចូរបង្រៀនគេនូវពាក្យផ្សេងៗ ។ ចូរផ្តើមជាមួយពាក្យដែលបបូរមាត់ធ្វើចលនាច្រើន និងងាយប្រាប់ដោយផ្អែក ។ ចូរជ្រើសរើសរកពាក្យដែលអ្នកប្រើញឹកញាប់ជាមួយគេនៅក្នុងល្បែងកំសាន្ត និងសកម្មភាពប្រចាំថ្ងៃ ។ នៅពេលដែលអ្នកនិយាយជាមួយគេ ចូរឱ្យច្បាស់ថា គេកំពុងមើលមុខ និងមាត់របស់អ្នក ។ ចូរប្រើសញ្ញាណដៃ នៅពេលដែលគេមិនអាចយល់ពាក្យ ។ ប៉ុន្តែចូរប្រើសញ្ញាណបន្ទាប់ពីនិយាយពាក្យ មិនមែនក្នុងពេលតែមួយទេ ។ កុមារមិនអាចមើលសកម្មភាពទាំងពីរក្នុងពេលតែមួយបានទេ ។

អ្នកអាចលេងល្បែងកំសាន្តជាមួយកុមាររួមជាមួយកុមារដែលស្តាប់លឺ ដោយប្រើ "របាំត្រាប់" គឺថា សំដែងអ្វីៗ និងនិយាយពាក្យដោយប្រើមាត់ ដោយពុំបញ្ចេញសំលេង ។

ជាសំណាងអាក្រក់ សំលេង និងពាក្យមួយចំនួនមើលទៅឃើញបបូរមាត់ ធ្វើចលនាស្រដៀងគ្នាយ៉ាងខ្លាំង ដូចជាសូរសំលេង 'k', 'g' និង 'h' មើលទៅដូចគ្នា ។ 'p', 'b', និង 'm' មើលទៅស្ទើរតែដូចគ្នា ។ 't', 'd', 's' និង 'z' មើលទៅដូចគ្នា ។ ហើយ 'ch' និង 'j' ក៏ដូចគ្នាដែរ ។ ដើម្បីប្រាប់កុមារបំណែកពាក្យស្រដៀងគ្នា ចូរប្រើសញ្ញាណដៃ ឬផ្តល់សញ្ញាណតូចៗឱ្យគេដូចជា ស្ទាបផ្នែកនៃសរីរាង្គកាយ សំលៀកបំពាក់ ឬអាហារ ។ ឧទាហរណ៏:

ប្រសិនបើម៉ាម៉ាពាក់ចំនុចមួយនៅលើជញ្ជើមរបស់គាត់

ហើយប៉ាប៉ាមានសំឡាកនៅថ្ពាល់ម្ខាង

នៅពេលនរណាម្នាក់នៅក្នុងផ្ទះនិយាយពីពួកគាត់ គេអាចផ្តល់ "សញ្ញាណឥទ្ធិពល" ផងដែរ ។



### ការការពារពីភាពថ្លង់

- ចូរចាត់វិធានការដើម្បី**ការពារជំងឺបៅត្រចៀក** (ចូរបង្រៀនកុមារកុំឱ្យញើសសំបោរខ្លាំង នៅពេលដែលគេកើតជំងឺផ្ដាសាយ)។ **ចូរព្យាបាលជំងឺជំងឺបៅត្រចៀកភ្លាម** នៅពេលដែលកុមារកើតជំងឺនេះ។ ប្រសិនបើកុមារកើតមានជំងឺជំងឺបៅត្រចៀកញឹកញាប់ ចូរទៅជួបគ្រូពេទ្យ ឬ "វេជ្ជបណ្ឌិតឯកទេសខាងត្រចៀក"។ ចូរកុំដាក់ស្លឹកឈើ ឬញាត់សំឡីនៅក្នុងត្រចៀកជំងឺបៅ។ ចូរឱ្យខ្ទុះហូរចេញមកក្រៅ។ ចូរមើលទំព័រ ១២៧ ***នៅកន្លែងដែលគ្មានវេជ្ជបណ្ឌិត*** ។
- **អំឡុងពេលមានផ្ទៃពោះ ចូរកុំពិសារឱសថ ដែលអាចប៉ះពាល់ដល់ទារក។** ចូរប្រាប់គ្រូពេទ្យ ឬវេជ្ជបណ្ឌិតថា អ្នកមានផ្ទៃពោះ និងសុំឱ្យគាត់ពិនិត្យ ក្រែងលោឱសថដែលគាត់ចេញវេជ្ជបញ្ជា ត្រូវបានផ្ដល់អនុសាសន៍អំឡុងពេលមានផ្ទៃពោះ។
- **ចូរចាក់វ៉ាក់សាំង** ក្មេងស្រី និងស្ត្រីការពារ**រោគកញ្ជ្រិល** (rubella) មុនពេលដែលពួកគេមានផ្ទៃពោះ (ប៉ុន្តែមិនមែនពេលមានផ្ទៃពោះឡើយ)។ ឬឱ្យក្មេងស្រីកើតជំងឺកញ្ជ្រិល ដោយឱ្យពួកគេលេង ឬដេកជាមួយកុមារដែលកើតជំងឺកញ្ជ្រិល។ វិធីនេះនឹងធ្វើឱ្យពួកគេទទួលបានវ៉ាក់សាំងធម្មជាតិ។ ស្ត្រីដែលមានផ្ទៃពោះគួរជៀសវាងកុំនៅជិតអ្នកដែលកើតជំងឺកញ្ជ្រិល។
- ចូរពិនិត្យថ្នាំឱ្យបានទៀតទាត់**អំឡុងពេលមានផ្ទៃពោះ**
- **ចូរពិសារអាហារឱ្យបានល្អតាមដែលអាចធ្វើទៅបានមុនពេល និងអំឡុងពេលមានផ្ទៃពោះ** ដោយប្រើ **អំបិលដែលមានអ៊ីយ៉ូត** និងរួមមានអាហារ**ដែលសំបូរជាតិដែក** និង **វីតាមីន** និង**រ៉ែជាច្រើនទៀត**។
- ចូរស្វែងរកសញ្ញាណរិកលរោគបណ្ដាលមកពីក្រពេញសៃរ៉ូយនៅលើកុមារ និងធ្វើការព្យាបាលឱ្យបានលឿន (ចូរមើលទំព័រ ២៨២)។
- **ចូរប្រយ័ត្នជាមុនដើម្បីការពារការខូតខួរក្បាល និងជំងឺខូចខួរក្បាលបញ្ហាចលនា** (ចូរមើលទំព័រ ១០៧ និង ១០៨)។
- **ចូរកុំដាក់** ឬអនុញ្ញាតឱ្យកុមារដាក់ **ភួងវត្ថុក្នុងត្រចៀក**។
- **ចូរជៀសវាង** នៅជិត**សំលេងដែលលឺខ្លាំង**។ នៅពេលដែលកុមារមិនអាចជៀសសំលេងនោះ ចូរបង្រៀនគេឱ្យខ្ទប់ត្រចៀករបស់ខ្លួន ឬប្រើប្រដាក់ញុកត្រចៀក។




### ពាក្យសំរាប់គ្រួសាររបស់កុមារថ្លង់

កុមារថ្លង់អាចធំធាត់ជាកូនប្រុស និងស្រីគួរឱ្យស្រលាញ់ និងមានប្រយោជន៍ ដូចកុមារដទៃទៀតដែរ។ ចូរព្យាយាមធ្វើឱ្យកូនរបស់អ្នកធំធាត់ឡើង។ ចូរផ្ដល់សិទ្ធិ និងការទទួលខុសត្រូវដល់គេ ដូចកុមារដទៃទៀតដែលមានវ័យដូចគ្នា។

ប្រសិនបើមានឱកាសសំរាប់កូនរបស់អ្នកដើម្បីទៅសាលាសំរាប់មនុស្សថ្លង់ ប្រសិនបើគេហាក់ដូចជាត្រឹមត្រូវ ចូរព្យាយាមអនុញ្ញាតិឱ្យគេទៅចុះ។ កុមារថ្លង់រៀនតាមវិធីផ្សេងពីកុមារដ៏ទៃ។ សាលាពិសេសអាចផ្ដល់ឱកាសច្រើន។ ប៉ុន្តែ បើកូនរបស់អ្នករៀនបានល្អនៅឯសាលាក្នុងភូមិ ដោយមានគ្រូបង្រៀនដែលយល់ និងជួយគេ និងមានមិត្តភ័ក្តិច្រើន នោះគេអាចរៀនបានប្រសើរនៅទីនោះ។ ចូរជួយគេឱ្យយល់ពីជំរើស និងមើលអ្វីដែលគេគិតអាចជារឿងល្អបំផុត។ ចូរច្បាស់ថា គេដឹងថាគេមានគ្រួសារដែលគួរឱ្យស្រលាញ់ជួយលើកទឹកចិត្តដល់គេ។

បន្ទាប់ពីពួកគេបញ្ចប់ការសិក្សា កុមារថ្លង់អាចធ្វើការងារបានច្រើនប្រភេទ។ មនុស្សថ្លង់អាចក្លាយជាគណនេយ្យករ គ្រូបង្រៀន មេធាវី អ្នកចំការ គ្រូពេទ្យ ស្មៀន សិប្បករជំនាញ និងវេជ្ជបណ្ឌិត។ វាមានតំលៃចំពោះការប្រឹងប្រែងដើម្បីមើលឃើញថាកុមារ និងមនុស្សជំទង់ថ្លង់ ទទួលបានការបណ្ដុះបណ្ដាល និងស្វែងរកការងារ។

ចូរប្រយ័ត្នថា បន្ទាប់ពីគេធំឡើង អ្នកមិនត្រូវបំពេញចិត្តគេដូចជាកូនក្មេងឡើយ។ គេអាចក្មេងជាងវ័យរបស់ខ្លួន។ ប៉ុន្តែវិធីល្អបំផុតដើម្បីជួយគេឱ្យធំធាត់ឡើង គឺត្រូវរំពឹងថាគេនឹងធំធាត់ឡើង។

នៅពេលដែលកុមារថ្លង់ចាស់ល្មមដើម្បីរៀបការ គេតែងតែជ្រើសរើសអ្នកដែលថ្លង់ឯទៀត ព្រោះពួកគេអាចយល់គ្នាបានប្រសើរ។ ពួកគេអាចមានកូន និងចិញ្ចឹមកូនទាំងអស់បានល្អ។ ជាធម្មតាម្ដាយ និងឪពុកថ្លង់មានកូនដែលមានសោតល្អ។

វាពិបាកដើម្បីក្លាយជាមនុស្សថ្លង់។ អ្នកអាចជួយមនុស្សដែលថ្លង់ ដោយអោយពួកគេធ្វើការទំនាក់ទំនងតាមវិធី ដែលគេគិតថាងាយស្រួល និងដោយព្យាយាមរៀនធ្វើទំនាក់ទំនងជាមួយពួកគេដោយខ្លួនឯង។